**TKI0751**

# សម្ភាសន៍ជាមួយ អ្នង ផន ភេទប្រុស អាយុ៥០ឆ្នាំ

## មុខងារៈ ប្រធានភូមិកកោះ

## រស់នៅភូមិកកោះ ឃុំអន្លង់ប្រាសាទ ស្រុកគិរីវង់ ខេត្តតាកែវ

## ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ជី ទេវិទ្ធ

## ០១:០៩:២៤

## ៣៥ទំព័រ

ទេវិទ្ធ : ថ្ងៃនេះថ្ងៃ១៤ ខែកក្កដា ឆ្នាំ២០១០ តា ដំបូងសុំណែនាំខ្លួនខ្ញុំសិន ខ្ញុំឈ្មោះជី ទេវិទ្ធ ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជានឹង ជាកន្លែងអង្គការទេ ដែលប្រមូលចងក្រងឯកសារប្រវត្តិសាស្ត្រកាលពីសម័យខ្មែរក្រហម យើងប្រមូលទុក យើងចងក្រងទុក ដើម្បីឲ្យក្មេងៗបានរៀនសូត្រក្រោយៗ ។ អីចឹងហើយបានត្រូវជាយើងកត់ត្រាទុករឿងរ៉ាវអស់នឹង ។ ខ្ញុំមកថ្ងៃនេះ ចង់សុំសម្ភាសន៍តាបន្តិចពីប្រវត្តិរបស់តា កាលពីសម័យខ្មែរក្រហមអីចឹង តាចាំប្រាប់ថាចាំមក តាភ្លេចប្រាប់ថាភ្លេចអត់អីទេ ។ អីចឹងខ្ញុំសុំសម្ភាសន៍តាបានទេ តា?

ផន : ថឺបាន ។

ទេវិទ្ធ : អត់អីទេ?

ផន : អឺ!

ទេវិទ្ធ : តាដំបូង ចង់បានឈ្មោះសិន តាឈ្មោះអី?

ផន : អ្នួន ផន ។

ទេវិទ្ធ : តាសព្វថ្ងៃអាយុប៉ុន្មានហើយ?

ផន : ៧៥ ។

ទេវិទ្ធ : ៧៥ឆ្នាំ?

ផន : អឺ! ៧៥ ។

ទេវិទ្ធ : សព្វថ្ងៃតារស់នៅភូមិឃុំស្រុកខេត្តអីដែរ?

ផន : ឃុំអន្លង់ប្រាសាទ ភូមិពោធិ៍តាម៉ុក អានឹងដាក់ភូមិខ្ញុំភូមិកកោះ ផ្លូវទៅនៅជាប់ភូមិពោធិ៍

តាម៉ុកទាំងមូល ។ ភូមិខ្ញុំដែលនៅពីដើមកាលជំនាន់ខ្មែរក្រហមមក ភូមិកកោះនឹងម៉ង ។

ទេវិទ្ធ ៖ អ៊ីចឹងតាត្រឡប់មកភូមិតាវិញ?

ជន ៖ បាទ! មកភូមិ ។

ទេវិទ្ធ ៖ ភូមិនេះ ភូមិអីគេ?

ជន ៖ ភូមិកកោះ ។

ទេវិទ្ធ ៖ ភូមិកកោះ ឃុំ?

ជន ៖ ឃុំអង្គប្រាសាទ ។

ទេវិទ្ធ ៖ ស្រុក?

ជន ៖ ស្រុកគិរីវង់ ខេត្តតាកែវដូចគ្នា ។

ទេវិទ្ធ ៖ ស្រុកគិរីវង់ ខេត្តតាកែវ?

ជន ៖ អឺ!

ទេវិទ្ធ ៖ តាចង់និយាយប្រវត្តិតាតាំងពីក្មេងមក ស្រុកកំណើតតាកើតជានៅខាងណា?

ជន ៖ នៅនេះ ពីកើតមកនៅភូមិកើត ប៉ុននៅភូមិនឹងដដែល ។

ទេវិទ្ធ ៖ ខាងកើតនេះ នៅក្បែរនេះ?

ជន ៖ បៀតក្បែរថ្មល់នឹង អានឹងគេហៅភូមិត្រពាំងត្រាវ ។

ទេវិទ្ធ ៖ ត្រពាំងត្រាវ?

ជន ៖ អឺ! ភូមិ ។

ទេវិទ្ធ ៖ ចុះឪពុកម្តាយតាកាលនឹងគាត់ធ្វើអី កាលតានៅក្មេង?

ជន ៖ ធ្វើអីទេ គាត់ស្លាប់តាំងពីនៅក្មេង ។

ទេវិទ្ធ ៖ គាត់ស្លាប់តាំងពីតានៅក្មេង?

ជន ៖ ស្លាប់មុនខ្មែរក្រហម ។

ទេវិទ្ធ ៖ គាត់ស្លាប់តាំងពីតាអាយុប៉ុន្មានដែរ?

ជន ៖ ស្លាប់ញោមប្រុសខ្ញុំស្លាប់អាយុខ្ញុំ១៣ ហើយញោមស្រីស្លាប់ខ្ញុំអាយុ២២ហើយ ។

ទេវិទ្ធ ៖ តាហៅញោមប្រុស ញោមស្រី តាធ្លាប់បួស?

ជន ៖ បួស ។

ទេវិទ្ធ ៖ បួសពីអង្កាល់?

ជន ៖ បួសតាំងពីជំនាន់សីហនុ ។

ទេវិទ្ធ ៖ ជិនាន់សីហនុ?

ផន ៖ អឺ!

ទេវិទ្ធ ៖ ចូលបួសៗនៅវត្តណា?

ផន ៖ វត្តទេពប្រណមនេះ ។

ទេវិទ្ធ ៖ ទេពប្រណម អូ!ឆ្ងាយដែរ?

ផន ៖ លើភ្នំ ។

ទេវិទ្ធ ៖ ទេពប្រណម បួសនៅនឹងបានប៉ុន្មានឆ្នាំ?

ផន ៖ បួសបានពាឆ្នាំ ហើយរៀនក៏រៀនពីក្មេងមកក៏នៅវត្តនឹងដែរ ចាប់តាំងពីអាយុ១៨ តាំងពីញោមស្លាប់ ។

ទេវិទ្ធ ៖ តាចាំទេ ញោមប្រុសឈ្មោះអីគេ?

ផន ៖ ឈ្មោះ តាអួន ។

ទេវិទ្ធ ៖ ត្រកូលគាត់ចាំទេ?

ផន ៖ ថីមិនចាំ ។

ទេវិទ្ធ ៖ ត្រកូលអីគេ?

ផន ៖ ប្រេស ។

ទេវិទ្ធ ៖ ប្រេស អួន?

ផន ៖ អឺ!

ទេវិទ្ធ ៖ ចុះញោមស្រី?

ផន ៖ ញោមស្រីនែក! អ៊ុក ប៊ុន ។

ទេវិទ្ធ ៖ ដល់ពេលតាយកត្រកូលតាមណា?

ផន ៖ យកតាមឪពុកខ្ញុំ ។

ទេវិទ្ធ ៖ ឈ្មោះអីវិញតា?

ផន ៖ ខ្ញុំដាក់រាល់ថ្ងៃ តាំងពីចៅនេះចេះតែអួនៗដែរ ។

ទេវិទ្ធ ៖ អួនទាំងអស់?

ផន ៖ អួន ផន អួន លីអីណា ។

ទេវិទ្ធ ៖ ដល់ពេលតាអួនអីគេ?

ផន ៖ ខ្ញុំ អួន ផន។

ទេវិទ្ធ ៖ កាលនឹងតាថារៀនពាឆ្នាំ សឹកវិញ?

ផន ៖ សឹក ។

ទេវិទ្ធ ៖ បួសរៀនពាឆ្នាំសឹកវិញ ហេតុអីបានសឹកកាលនឹង?

ផន ៖ សឹកមកពីចេះ កាលនឹងជំនាន់លន់ នល់ ហើយកាលបួសនឹងជំនាន់សីហនុជិតចប់ ជិតគាត់ឈប់ហើយ ។

ទេវិទ្ធ ៖ គាត់គេរដ្ឋប្រហារ?

ផន ៖ អឺ! ហើយសឹកមកដល់មកនៅលន់ នល់ ហើយការក៏ការនៅរបបលន់ នល់ដែរ សង្គមលន់ នល់ ។

ទេវិទ្ធ ៖ ការពីសម័យលន់ នល់ដែរ?

ផន ៖ អឺ! ជំនាន់លន់ នល់ ។

ទេវិទ្ធ ៖ ម៉េចបានតាសឹក?

ផន ៖ សឹកមកពីចេះទេ ញោមនឹងនៅតែញោមស្រី ហើយដល់អីចឹងបងខ្ញុំវាមានរឿងចេះចុះគេចោទថាគេលួចនេះលួចនោះគេអីចឹង គេយកទៅដាក់គុកតាកែវនោះ ។ ហើយដល់អីចឹងទៅគ្មានអ្នកណាថែទ្រព្យរបស់អីចឹង មើលពីវត្តទៅ ចុះផ្ទះនៅជិតនឹង មើលទៅឃើញវេទនាពេកក៏សឹកទៅសុំលោកគ្រូសង្ឃរាជ គ្មានរឿងអីទេមានតែប៉ុននឹង ។

ទេវិទ្ធ ៖ សឹកទៅជួយមើលផ្ទះថែទាំឪពុកម្ដាយ?

ផន ៖ អឺ!ជួយមើលគោក្របី ឃើញម្ដាយនឹងដឹកក្របីដៃ២ ហើយក្របីចេះឡើង-ក វាយ៉ាប់អីចឹងកុំអីមិនទាន់សឹកទេ ខ្ញុំមិនស្ទូវ ។

ទេវិទ្ធ ៖ ដល់ពេលដឹកហើយបានយូរទេ បានរៀបការ?

ផន ៖ សឹកបាន២ឆ្នាំ ។

ទេវិទ្ធ ៖ សឹកបាន២ឆ្នាំ រៀបការ?

ផន ៖ អឺ!

ទេវិទ្ធ ៖ ហើយបានអំស្រីនឹងឯង?

ផន ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ អូ! យូរហើយអីចឹង ។ ចុះប្រពន្ធតាឈ្មោះអីគេ?

ផន ៖ ឯក សេង ។

ទេវិទ្ធ ៖ ហែក សេង?

ជន ៖ ឯក សេង ។

ទេវិទ្ធ ៖ ឯក សេង?

ជន ៖ អានឹងយកជីតាគេ បើតាមឪគេយិន ឯក យិន ឯក សេង ។

ទេវិទ្ធ ៖ គារៀបការអាយុប្រហែលប៉ុន្មាន?

ជន ៖ ខ្ញុំការអាយុ២២ ។

ទេវិទ្ធ ៖ ២២ឆ្នាំ?

ជន ៖ បាទ!

ទេវិទ្ធ ៖ ក្មេងដែរ?

ជន ៖ ក្មេង ហើយប្រពន្ធខ្ញុំអាយុ១៦ ។

ទេវិទ្ធ ៖ ចុះគាចូលបដិវត្តនឹងគេឆ្នាំណា?

ជន ៖ ចូលបដិវត្ត មើលចូលពីឆ្នាំ មើលឆ្នាំ៧៥ ។

ទេវិទ្ធ ៖ ៧៥ ពេលបែកភ្នំពេញ?

ជន ៖ បែកភ្នំពេញ ។

ទេវិទ្ធ ៖ គាចូលប្រហែលឆ្នាំណា ក្រោយរដ្ឋប្រហារលន់ នល់នឹងប្រហែលបានប៉ុន្មានឆ្នាំ ការហើយបានប្រហែលប៉ុន្មាន?

ជន ៖ កាលម៉ាចំបក់នឹង យើងកាលនឹងជំនាន់ឥស្សរៈណា៎ ឥស្សរៈចប់ទៅមិនលន់ នល់ៗវាដេញអាខ្មែរក្រហម អានឹងគេហៅឥស្សរៈខ្មែរក្រហមដែរ កាលនឹងចូលបានប្រហែលជាមើលតាំងពីនឹងមក ។

ទេវិទ្ធ ៖ គាចូលតាំងពីសម័យឥស្សរៈមកម៉េះ?

ជន ៖ អឺ! ចូលតាំងពីនឹង ។

ទេវិទ្ធ ៖ វៃបារាំងវៃអី?

ជន ៖ ហ្នឹងហើយ កាលនឹងនៅក្មេងទេ អត់ទាន់មានធ្វើអីការងារអីទេ ។

ទេវិទ្ធ ៖ ចុះដែលចូលៗបដិវត្ត?

ជន ៖ ទៅជំនាន់លន់ នល់ បដិវត្តកាលនឹងខ្ញុំកអត់មានធ្វើអីនឹងគេដែរ ទើបនឹងធ្វើពេលនេះ ពេលខ្មែរក្រហម ។

ទេវិទ្ធ ៖ ពេលខ្មែរក្រហមហ្នឹងទេ?

ជន ៖ បាទ!

ទេវិទ្ធ : ប៉ុន្តែយើងចូលក្រុមនឹងតាំងពីឆ្នាំណាមកតាចាំទេ?

ផន : ក្រុមដែលធ្វើនឹង?

ទេវិទ្ធ : បាទ! អានឹងគេហៅចូលបដិវត្តអីចឹងហើយ?

ផន : អើ! អានឹងគេហៅបដិវត្តអីចឹងហើយ ។

ទេវិទ្ធ : ចូលនឹង?

ផន : ចូលមើល តាំងពីមុនបែករដ្ឋប្រហារ ចូលមុននឹងតាំងពីឆ្នាំ ដូច៧០ ៧១ ៧២ ។

ទេវិទ្ធ : ៧១ ៧២ ក្រែងតានៅបួសនៅឡើយ?

ផន : មិនទេ! ១៩៧២ ។ នៅបួសឯណា ៧២មានបួសឯណា ចូលដល់៧១ ៧២ ដល់៧៥មិនបែក ។

ទេវិទ្ធ : បែកភ្នំពេញ?

ផន : អឺ! ចូលតាំងពីនឹង ។

ទេវិទ្ធ : ចូលតាំងពី?

ផន : ៧១ ៧២ ។

ទេវិទ្ធ : តាសឹក បានប៉ុន្មានឆ្នាំ បានចូលនឹង?

ផន : សឹកបាន២ឆ្នាំ ។

ទេវិទ្ធ : អីចឹងតាសឹកប្រហែលជាឆ្នាំ៧០គត់?

ផន : ហ្នឹង ។

ទេវិទ្ធ : អាឆ្នាំរដ្ឋប្រហារនឹង?

ផន : បាទ! ឆ្នាំហ្នឹង ។

ទេវិទ្ធ : សឹកហើយក៏ចូលបដិវត្តទៅ?

ផន : អឺ!

ទេវិទ្ធ : ពេលចូលនឹងគេធ្វើម៉េចដែរ?

ផន : មានធ្វើអី ចូលត្រង់នឹង យើងនៅនឹង ចូលត្រឹមត្រូវ ។

ទេវិទ្ធ : គេធ្វើយ៉ាងម៉េចដែរ គេមានពិធី គេមានអីថាឥឡូវអ្នកនេះចូលជាសមាជិករបស់បដិវត្តយើងហើយ គេមានពិធីអីចឹង មានឡើងប្តេជ្ញាមានអី?

ផន : អឺ! គេមានអីចឹងដែរ វាមានសួរអីចឹងដែរ ។

ទេវិទ្ធ : គេធ្វើដែរ តាចូលៗខាងណាវិញ?

ផន ៖ ចូលខាងលន់ នល់ ។

ទេវិទ្ធ ៖ ចូលនៅកន្លែងណាដែរ?

ផន ៖ អាចូលនឹងនៅភ្នំ ។

ទេវិទ្ធ ៖ ភ្នំអីគេ?

ផន ៖ ភ្នំរន្ទះ ។

ទេវិទ្ធ ៖ ភ្នំរន្ទះជិតនេះ?

ផន ៖ ជិតនេះ ។

ទេវិទ្ធ ៖ អីចឹងកាលនឹងខាងខ្មែរក្រហមគេចុះមកឃោសនា ឃោសអី?

ផន ៖ នៅទេ កាលនឹងអត់ទាន់មាន ។

ទេវិទ្ធ ៖ ចូលតាមពីណាគេតា?

ផន ៖ ខ្មែរក្រហមមកនៅនឹងហើយបានចូលខ្មែរក្រហម ។ ខ្មែរក្រហមគេមកដេញរំដោះពីលន់ នល់ ទៅៗលិចរហូតទៅ ៧២ ។

ទេវិទ្ធ ៖ ៧២គេរំដោះយើងទៅខាងនោះ?

ផន ៖ អឺ!

ទេវិទ្ធ ៖ គេគៀរយើងទៅ?

ផន ៖ គៀរទៅលើ ។

ទេវិទ្ធ ៖ គៀរទៅលើខាងណាវិញ?

ផន ៖ ទៅឆ្ងាយនោះ មើលទៅពីឃុំភ្នំតូចទៅឆ្ងាយនឹងអន្លុះជ័យៗដល់នឹង ដល់ទៅអន្លុះជ័យបានតិច ថាត្រូវមកវិញ រំដោះឲ្យមកវិញ មកវិញមួយសារ ។ ដល់ក្រោយនឹងគេដេញឲ្យទៅទៀត ទៅបានប៉ុន្មានវស្សា ទៅបាន១ខែយួនគេបុកមកគេវៃរំដោះបានត្រឹមអន្លុះជ័យមកវិញ មក រហូត ។ យួនគេដេញបាញ់ ដេញច្នោងនឹង ស្កាត់ត្រឹមនឹង ។

ទេវិទ្ធ ៖ អានឹង៧៩?

ផន ៖ បាទ! ៧៩ ។

ទេវិទ្ធ ៖ អូ! តានិយាយកាត់លឿន ខ្ញុំចាំអត់ទាន់ ។ អីចឹងខ្មែរក្រហមចូលភូមិនេះតាំងពីឆ្នាំ៧២ម៉េះ ខាងប៉ុលពតនឹង គេចូលមកកាន់កាប់ភូមិនេះតាំងពីឆ្នាំណាដែរ?

ផន ៖ មើលចូលមកតាំងពី៧២ ។

ទេវិទ្ធ ៖ ៧២ អូ!ឆ្នាំនឹងតាចូលបេ្តជ្ញានឹងគេនៅភ្នំរន្ទះ?

ជន ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ តាចូលមុន បានគេចូលមកកាន់កាប់នៅនេះ?

ជន ៖ បាទ! អ៊ីចឹងហើយ ។

ទេវិទ្ធ ៖ ចូលទៅប្តូដ្យាទៅហើយបាន គេមកកាន់ភូមិនឹង ហើយបានគេជម្លៀសទៅ?

ជន ៖ អឺ!

ទេវិទ្ធ ៖ អ៊ីចឹងតាគេហៅអ្នកមូលដ្ឋាន?

ជន ៖ មូលដ្ឋាន បានដល់៧២ ៧៥មកខ្មែរក្រហមមកចូលមកដល់ភូមិនឹងវាចូលបាន២ឆ្នាំ ។ ចុះដល់៧៥ពួកភ្នំពេញមក រំដោះភ្នំពេញមក ដល់៧៩យើងមិនដាច់ មិនយើងចុះពីលើមកវិញ ពួក១៧ក៏គេបញ្ជូនទៅលើដែរ ប៉ុន្តខ្ញុំអត់ទៅ៧៩ ។

ទេវិទ្ធ ៖ តានិយាយរឿង៧២ នៅពេលដែលគេជម្លៀសតាទៅខាងលើនឹង តាថាទៅដល់អន្លុងជ័យ ទៅ៧២នឹង ទៅនៅអន្លុងជ័យនឹង ទៅបោះទីតាំងនៅនឹង?

ជន ៖ នៅភូមិចាស់ ភូមិអីគេ ផ្ទះគេ បៀតផ្ទះគេគ្រប់គ្នា ។

ទេវិទ្ធ ៖ គេឲ្យនៅនឹង?

ជន ៖ អឺ! យើងចេះតែនៅៗទៅដាក់រទេះដាក់គោនៅនឹង ។

ទេវិទ្ធ ៖ ទៅទាំងគ្រួសារ ទៅទាំងប្រពន្ធកូន?

ជន ៖ ទៅទាំងអស់រលីង ម៉ាភូមិនឹងទៅទាំង ។

ទេវិទ្ធ ៖ ទាំងអស់គ្នា?

ជន ៖ អឺ!

ទេវិទ្ធ ៖ តែតាពេលនឹងនៅជុំគ្នាប្រពន្ធកូន?

ជន ៖ ជុំគ្នាអត់មានបែក កូនខ្ញុំមកបែកមីមួយដែលថាធ្វើពេទ្យនឹង ដល់៧៥ហើយពួកភ្នំពេញមក ដល់ បានបញ្ជូនកូនខ្ញុំ ។ ៧៦បានកូនខ្ញុំគេបញ្ជូនទៅភ្នំពេញ ។

ទេវិទ្ធ ៖ កូនតាឈ្មោះអីគេ?

ជន ៖ អួន វ៉ាន់ ។

ទេវិទ្ធ ៖ ស្រី ប្រុស?

ជន ៖ ស្រី ។

ទេវិទ្ធ ៖ ពេលគេបញ្ជូនទៅនឹងអាយុប្រហែលប៉ុន្មាន?

ជន ៖ បាទ! អាយុ១៣ ។

ទេវិទ្ធ ៖ ១៣?

ផន ៖ ឥឡូវគិតមើលតាំងពីនឹង ឥឡូវ៣០ប៉ុន្មានហើយ ។

ទេវិទ្ធ ៖ ឥឡូវចង់៤០?

ផន ៖ អឺ!ជិត៤០ ។

ទេវិទ្ធ ៖ បើ១៣ឆ្នាំ ៤០ជាងហើយ បើ១៣ឆ្នាំវា៤០ស្ទើង?

ផន ៖ ៤០ហើយ ហើយដល់វាប្រែឈ្មោះគេហៅនុច ។

ទេវិទ្ធ ៖ ឈ្មោះគាត់ពិតប្រាកដអួន វ៉ាន់ ឈ្មោះបដិវត្តគេហៅនុច?

ផន ៖ នុច ។

ទេវិទ្ធ ៖ គេប្រាប់ថាម៉េចដែរ?

ផន ៖ គេប្រាប់ថា គ្មានបានប្រាប់ខ្ញុំ វានៅធ្វើដីដីបូកនោះ ធ្វើជាមួយពួកនាងទាំងអស់ ។ ទៅដល់គេទៅបំផុសបំផុល គេទៅនិយាយណែនាំថា ឲ្យកុមារទាំងអស់គ្នានឹង ទៅធ្វើពេទ្យយកប៉ុន្មានៗ ។ ដល់អីចឹង វាអត់មកប្រាប់ខ្ញុំផង ។

ទេវិទ្ធ ៖ គេប្រាប់ថាអីចឹង អ្នកដែលមកប្រាប់នឹងពីណាគេ?

ផន ៖ អង្គការគេអត់ប្រាប់ណា អានឹងមេឃុំគេ ពួកស្រុកគេ ស្រុកអាពត ពួកយាយបូ ពួកអីនឹងហើយឃុំយើងនឹង មើលគេនាំមកធ្វើឃុំនឹងតាង៉ែតៗយាយមុំ ។

ទេវិទ្ធ ៖ ឃុំនឹង ឈ្មោះតាង៉ែត?

ផន ៖ តាង៉ែតមកពីលើមក ដំណាក់ស្នួលមក មកធ្វើឃុំនឹង អាពតនឹង មកក្តាប់ពួកខ្ញុំ ។ ក្តាប់ពួកខ្ញុំហើយចាត់តាំងឲ្យខ្ញុំជាមូលដ្ឋាននឹង ឲ្យធ្វើប្រធានភូមិប្រធានក្រុម ក្តាប់ពួកភ្នំពេញគ អានឹងចូលបដិវត្ត ។

ទេវិទ្ធ ៖ ចុះតាកាលនឹង តាប្រធានក្រុម ប្រធានអី?

ផន ៖ មុនដំបូងប្រធានក្រុម ដល់តិចគេឲ្យធ្វើប្រធានភូមិ ។

ទេវិទ្ធ ៖ ប្រធានភូមិ?

ផន ៖ ក្តាប់ពួកភ្នំពេញទាំងអស់ ។

ទេវិទ្ធ ៖ ភូមិដែលតាក្តាប់នឹង ភូមិអីគេ គេហៅភូមិអីគេ?

ផន ៖ ភូមិកកោះ ។

ទេវិទ្ធ ៖ ភូមិហ្នឹងដដែល?

ផន ៖ អឺ! ភូមិនឹងដដែល ។

ទេវិទ្ធ : ចុះអ្នកភ្នំពេញមកនឹងច្រើននាក់ទេ?

ផន : មកនៅនឹងខ្ញុំនឹង៤៥គ្រួសារ ។

ទេវិទ្ធ : បើរាប់មនុស្សវិញប្រហែលប៉ុន្មាននាក់?

ផន : មនុស្សចូលរយហើយ តែម្នាក់៣ ម្នាក់៤ ម្នាក់២ អាខ្លះមកសុទ្ធមេម៉ាយ ប្ដីមិនដឹងបែកទៅណា បើខ្ទង់ជិត១០០ដែរនឹង ។

ទេវិទ្ធ : នៅក្នុងភូមិនេះ មានអ្នកថ្មី តែភ្នំពេញនឹងទេ មានអ្នកពីផ្សេងទៀតដែរ?

ផន : មានអ្នកកំពង់សោម ។

ទេវិទ្ធ : មានអ្នកកំពង់សោមមកដល់នឹងដែរ?

ផន : កំពង់សោមមកដល់នឹងគេបែកកំពង់សោមឲ្យភូមិនោះ ស្វាយធំអ្នកក្ដាប់ ហើយខ្ញុំនៅនេះ ។

ទេវិទ្ធ : អីចឹងនៅៗ?

ផន : ខ្ញុំក្ដាប់តែពួកភ្នំពេញទេ ។

ទេវិទ្ធ : អ៊ំក្ដាប់តែពួកភ្នំពេញទេ ៤៥គ្រួសារ?

ផន : បាទ! ពួកភ្នំពេញ ។

ទេវិទ្ធ : ហើយដាក់ឲ្យរស់នៅខាងណាវិញ អ្នកភ្នំពេញ?

ផន : នៅភ្នំពេញនៅនឹងម៉ង នៅគ្រប់គ្នា គ្រប់ផ្ទះ ហើយខ្ញុំធ្វើរោងឲ្យនៅតែពាស ។

ទេវិទ្ធ : ចុះអ្នកមូលដ្ឋានយើងនៅខាងណាវិញ?

ផន : នៅនឹងដដែល ។

ទេវិទ្ធ : ធម្មតាគេដាក់ឲ្យរស់នៅដាច់ដោយឡែកពីគ្នា?

ផន : អត់ទេ នៅនឹងគ្នា គ្រាន់ឲ្យខ្ញុំមើលការខុសត្រូវនឹងណា បែកបាយបែកទឹកអង្ករ ព្រោះមកគ្នាមានអីប្រគល់លើខ្ញុំ ។

ទេវិទ្ធ : ចុះអ្នកចាត់ចែង អ្នកណាអ្នកចាត់ចែង១៧មេសានឹងឲ្យទៅធ្វើការនេះធ្វើការនោះ?

ផន : អានឹងមេឃុំគេ ។

ទេវិទ្ធ : មេឃុំ?

ផន : មេឃុំតាង៉ែត ។

ទេវិទ្ធ : មេឃុំឈ្មោះអីគេ?

ផន : តាង៉ែត ។

ទេវិទ្ធ : ត្រកូលគាត់អត់ចាំ?

ផន ៖ ហ៉េ! តាអីទេ ក្មេចឪគាត់ តាង៉ែត យាយអី ហើយតាង៉ែតតិចគាត់ធ្វើដូចស៊ីសំណូកសូក ប៉ាន់ លោកពេកទៅគេដកគាត់ទៅនៅពោធិ៍កន្ទុយ នៅឃុំរាមអណ្ដើក ហើយបញ្ចូលឈ្មោះ តាមុំទៀតអនុគាត់ឡើងជាប្រធានវិញ ។

ទេវិទ្ធ ៖ ចុះតាមុំគាត់ឈ្មោះអីគេ ឈ្មោះពេញគាត់?

ផន ៖ ឈ្មោះពេញអានាមត្រកូល មិនដឹងនាមត្រកូលអីសោះ អីមុំនឹង ។

ទេវិទ្ធ ៖ តានៅប្រធានភូមិរហូតនៅដល់ដាច់?

ផន ៖ នៅដល់ចប់ ។

ទេវិទ្ធ ៖ ចុះអ្នកឃុំគេប្រាប់មកតា អីចឹងនៅភូមិយើងនេះមានឈ្មោះទាំងអស់ តាមានបញ្ជីឈ្មោះ?

ផន ៖ មានឈ្មោះទាំងអស់ ។

ទេវិទ្ធ ៖ មានបញ្ជីមួយដាក់ថាអ្នកភ្នំពេញ អ្នកនេះឈ្មោះអីៗ?

ផន ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ មានធ្វើប្រវត្តិរូបគេគ្រប់គ្នាទេ?

ផន ៖ ធ្វើគ្រាន់តែកត់តែឈ្មោះគេ ប៉ុនឥឡូវសៀវភៅអាឈ្មោះគេនឹងបាត់ នៅចាំឈ្មោះនឹងមាត់ ក្នុងចិត្ត ។

ទេវិទ្ធ ៖ ចុះសៀវភៅអស់នឹងទៅណា?

ផន ៖ សៀវភៅនឹងរបាត់រប៉ាយអស់ទៅ ដាច់អស់ ដុតចោលខ្លះ ។

ទេវិទ្ធ ៖ ដុត?

ផន ៖ ហើយដល់អីចឹងបែកអីចឹងដុតចោល ។

ទេវិទ្ធ ៖ អត់មាននៅសល់អី?

ផន ៖ គ្មាន ។

ទេវិទ្ធ ៖ មាននៅសល់រូបថត?

ផន ៖ គ្មានទេ សល់ នៅចាំតែឈ្មោះគេ ។

ទេវិទ្ធ ៖ នៅចាំឈ្មោះអីខ្លះ?

ផន ៖ ឈ្មោះមើលតាំងពីដំបូង តាឈុំ ១តាឈុំ ២អាសាំង ៣ធាយ ៤អាក្រឡុញ ៥អាសុខ ៦អាណាក់ ៧អានេះនៅភ្នំពេញ ស្លាប់ទៀត ។

ទេវិទ្ធ ៖ អ្នកអស់នេះ អ្នកណាចេះ អ្នកគេជម្លៀសមកនឹង អ្នក១៧មេសា?

ផន ៖ ជម្លៀសមកនេះអាខ្លះនៅទម្លាប់ អាខ្លះនៅឆ្ងាយស្រុកយួន អាខ្លះនៅកំពង់សោម ចិនរាប់ៗ មិនអស់ច្រើន ភ្លេចឈ្មោះនឹងខ្លះ ។ យាយនេះ ម៉ែមឿននៅភ្នំពេញ ។

ទេវិទ្ធ ៖ គាអ្នកដើរស្រង់ឈ្មោះគេ ឬក៏អ្នកណាគេអ្នកដើរស្រង់ឈ្មោះគេនឹង?

ផន ៖ មិនទេ មេឃុំគេៗឲ្យចុះឈ្មោះឲ្យ ។

ទេវិទ្ធ ៖ មេឃុំគេប្រើយើង?

ផន ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ គាង៉ែតនឹងកាលនឹង?

ផន ៖ អឺ! គាង៉ែត ។

ទេវិទ្ធ ៖ អីចឹងយើងដើរកត់ទៅ ម៉ាផ្ទះមានប៉ុន្មាននាក់អីចឹងក្មេងចាស់?

ផន ៖ អឺ! ហ្នឹងហើយឈ្មោះយុវជនមានប៉ុន្មាននាក់ ទាហានមានប៉ុន្មាន?

ទេវិទ្ធ ៖ នៅក្នុងបញ្ជីនឹងមានគេមានអីខ្លះ មានតែឈ្មោះ មានសមាជិកគ្រួសារ ហើយមានអីទៀតនៅក្នុងបញ្ជីនឹង?

ផន ៖ គ្មានស្អី គ្រាន់កត់ចេះ ដូចថាឥឡូវអ្នកណាធ្វើទាហាន សក្តិប៉ុន្មានៗគេឲ្យជ្រាវនឹងទៀត តែអានឹងក៏ខ្ញុំអត់បានជ្រាវដែរ ម៉េមាយៗខ្ញុំមិនសួរស្រីៗ ប៉ុនសួរប្តីអ្នកឯងធ្វើអីៗអីចឹង ។ ហើយមកនៅនឹងខ្ញុំ ឥឡូវអាហាលនៅភ្នំពេញ កាលនឹងវាធ្វើខាងរទេះភ្លើង ប្រធានថ្នល់រទេះភ្លើង មីស្រីនឹងគ្មានធ្វើអីទេ នៅក្មេងល្មម ហាលហ្នឹងគេធ្វើការធំៗដែរ ហើយយាយអូន គាធន គេសុទ្ធទាហានសក្តិ២ សក្តិ៣ មកនៅនឹងខ្ញុំ ។ អានឹងគេមកដល់ឲ្យខ្ញុំសួរអីចឹង ប៉ុនខ្ញុំអត់មានសួរទេ ហ្នឹងគាង៉ែតឲ្យសួរ ដល់ហើយពិនិត្យលិខិតមើលអាណាធ្វើអី ខ្ញុំថា«ទេសួរទៅគេថាធ្វើនេះធ្វើនោះធ្វើពេទ្យធ្វើអី មិនដឹងអ្នកណាធ្វើអី ខ្ញុំមិនដឹងទៅសួរម៉េច គ្រាន់ប៉ុននឹង» ។

ទេវិទ្ធ ៖ កត់បញ្ជីនឹងគេ កត់រួច?

ផន ៖ គេកត់ដើម្បីចម្រាញ់យកអាណាធ្វើទាហាន អាណាធ្វើអីនាយទុនអីណា ណាគេស្រង់យកទៅវៃចោល ។

ទេវិទ្ធ ៖ គេស្រង់យកទៅ?

ផន ៖ អឺ! និយាយអីចឹង ។

ទេវិទ្ធ ៖ គេយកទៅដាក់នៅណា?

ផន ៖ យកទៅព្រៃប្រធាតុ ។

ទេវិទ្ធ ៖ មន្ទីរអីគេ?

ផន ៖ មន្ទីរអប់រំគេនៅវត្តប្រធាតុ ។

ទេវិទ្ធ ៖ វត្តប្រធាតុនឹងនៅក្នុងភូមិឃុំអីដែរ?

ផន ៖ ឃុំគោកព្រិច ។

ទេវិទ្ធ ៖ ឆ្ងាយពីនេះទេ?

ផន ៖ ឆ្ងាយ នៅខាងលិចបឹង ។

ទេវិទ្ធ ៖ ខាងលិចបឹង?

ផន ៖ អឺ!

ទេវិទ្ធ ៖ ចុះឥឡូវមន្ទីរនឹងនៅមានសល់អីខ្លះ?

ផន ៖ មន្ទីរនឹងមិនសល់ម៉េចទៅអាកន្លែងគេនឹង គ្រាន់ក្បាលខ្មោចនឹងរាប់ទៅ៣០០ ។

ទេវិទ្ធ ៖ ក្បាល?

ផន ៖ យកទៅវៃចោលនឹង ក្បាលនឹងគេដាក់ក្នុងសាលាលោកនឹង គេតម្រាប់គរនៅនឹងខ្ញុំទៅមើលដែរដល់ហើយចប់ ។ ហើយដល់អីចឹងទៅ លោកគ្រូនឹងក៏គាត់មិនយកទៅចោលណាដែរ លោកធ្វើមុងមួយ ធ្វើបន្ទប់មួយដាក់ក្នុងនឹងទាំងអស់ក្បាលមនុស្សនឹង ដល់ហើយលោកផ្សាបិទជិតឈឹងគ្មានអ្នកណាទៅមើលបាន ។

ទេវិទ្ធ ៖ អូ! ផ្សាបិទតែម្តង?

ផន ៖ អឺ! បិទចាក់សោរ ចាក់អីរបិទទ្វារ ។

ទេវិទ្ធ ៖ តែមានកញ្ចក់ទេ?

ផន ៖ អត់ទេ អត់មានពីណាទៅមើលបាន ។

ទេវិទ្ធ ៖ អីចឹងមើលអត់ឃើញផង?

ផន ៖ មើលមិនឃើញ មើលពីក្រៅអត់ឃើញ ។

ទេវិទ្ធ ៖ ប្រធាតុនឹងមន្ទីរអីគេ មន្ទីរស្រុក មន្ទីរឃុំ?

ផន ៖ មន្ទីរស្រុកគេ ។

ទេវិទ្ធ ៖ ស្រាប់ស្រុកគីរីវង់?

ផន ៖ អានឹងគេហៅថាមន្ទីរនគរបាលគេ ។

ទេវិទ្ធ ៖ មន្ទីរនគរបានស្រុក?

ផន ៖ អឺ! នគរបាលគេសុទ្ធតែអ្នកគេធ្វើប៉ូលីសទាហាន គេហៅប្រធាននគរបាល ។

ទេវិទ្ធ ៖ ចុះតានៅឈ្លបនៅភូមិនេះមានឈ្លបប៉ុន្មាននាក់ កាលនឹង?

ជន ៖ កាលនឹងមាន៣-៤នាក់ ។

ទេវិទ្ធ ៖ ឈ្លបនឹង?

ជន ៖ ទេ! អាអ្នកធ្វើខ្មែរក្រហមនឹងមាន នេះគ្មានទេ ឈ្លបមានឈ្លបឃុំយើង ។

ទេវិទ្ធ ៖ ឃុំ?

ជន ៖ ហ្នឹង ។

ទេវិទ្ធ ៖ ចុះភូមិអត់មាន?

ជន ៖ គ្មានទេ ។

ទេវិទ្ធ ៖ ភូមិអាចមានឈ្លបទេ?

ជន ៖ អត់មាន ។

ទេវិទ្ធ ៖ អីចឹងឃុំ?

ជន ៖ មានតែឃុំ ។

ទេវិទ្ធ ៖ ម៉ាឃុំមានប៉ុន្មាននាក់?

ជន ៖ មាន១២នាក់ ១០នាក់ ។

ទេវិទ្ធ ៖ អាចតាមនឹង?

ជន ៖ អឺ! អានឹងគេនៅនឹងដូចគ្នា ។

ទេវិទ្ធ ៖ ហើយឃុំនឹង ឈ្លបទាំងអស់នឹងអ្នកណាគេអ្នកទទួលខុសត្រូវ អ្នកណាគេអ្នកកាន់កាប់អីចឹង?

ជន ៖ អានឹងកាលនឹងជំនាន់នេះនឹង ជំនាន់មេឃុំនៅនោះដំបូងគេ ។

ទេវិទ្ធ ៖ ផ្ទើតនឹង?

ជន ៖ ហ្នឹងហើយ ផ្ទើតហើយមេឃុំយើង យ៉េស!តាអី អាមេឃុំទោក-៥នឹងមិនងាប់ គេយកមកវិញ យកតែខ្មោចមក គេរុំដាក់ឡាំង ។

ទេវិទ្ធ ៖ អូ! គាត់ទោក-៥?

ជន ៖ ទោមេឃុំនឹងគេហៅទោក-៥នាំអ្នកស្រុកនឹងទៅ ។

អ្នកជិតខាង៖ គាត់ អ៊ំយន់?

ជន ៖ អឺ! អ៊ំយន់ កូនខ្ញុំក៏ទៅដែរ មកវិញចាញ់ឈឺចង់ងាប់ចង់រស់ ព្រោះខ្ញុំកាលនោះខ្ញុំធ្វើប្រធានភូមិ បើយើងមិនហ៊ានចំណាយកូនយើងឲ្យទៅ ក៏មិនកើត ។

ទេវិទ្ធ ៖ គេថាយើងអត់បរិច្ចាគ?

ផន ៖ អឺ! យើងដេញតែគេទៅក៏មិនកើត កូនខ្ញុំវាសុខចិត្តទៅ អានឹងទៅលើយួនវានៅត្រួតត្រាណាស់ដែរ វាសែងរបួសសែងអីទៅវើនៅនឹង ។ ហើយអានឹងយុំយើងមានហើយនឹង ។

ទេវិទ្ធ ៖ ចុះអ្នកនិយាយរឿងអ្នកនៅភូមិនេះវិញ ប្រជាជនថ្មីគេឲ្យទៅធ្វើអីខ្លះកាលនឹង?

ផន ៖ ធ្វើៗលើកប្រឡាយពួក១៧ ។

ទេវិទ្ធ ៖ អូ! ប្រឡាយនៅមុខនេះ?

ផន ៖ ហ្នឹង ។

ទេវិទ្ធ ៖ អីចឹងប្រឡាយនឹងមានយូរហើយ?

ផន ៖ យូរហើយ ។

ទេវិទ្ធ ៖ គេហៅប្រឡាយអី?

ផន ៖ ដល់ហើយពួកនឹងមក ទេ!ពួកនឹងមិនទាន់បានធ្វើអានឹងទេ ធ្វើតែពួកមូលដ្ឋានទេ ប្រឡាយនឹងដល់ពួកនឹងមកបានចាប់ធ្វើប្រឡាយណាៗទៀតនោះ ពួក១៧នឹង ។

ទេវិទ្ធ ៖ ឲ្យទៅជីកប្រឡាយ?

ផន ៖ ធ្វើប្រឡាយនេះ មូលដ្ឋាននឹងធ្វើ ធ្វើនេះមិនយូរ ដល់ពួកបែកភ្នំពេញគេឃើញប្រឡាយនឹងគេថា«ចុះនរណាពូកែជីកប្រឡាយនឹងម៉េច ជីកស្រួល ជីកនឹងម៉ាស៊ីន ជីកនឹងកម្លាំង?» ថា«គេជីកនឹងកម្លាំងតើ» ហើយអានឹងតាង៉ែតនឹងមកក្តាប់ហើយណា សន្តមខ្មែរក្រហមនឹងមក បានឲ្យមូលដ្ឋាន អានឹងមិនទាន់មានពួក១៧មក ។ ដល់អីចឹងគេឲ្យធ្វើស្រាប់តែគេហៅឲ្យទៅធ្វើប្រឡាយនោះទៀតៗ ចុយម៉ែ!អីចឹងហើយបានធ្វើបាន ហើយធ្វើនឹងស៊ីបបរទៀតយ៉ាប់ណាស់ ។

ទេវិទ្ធ ៖ ស៊ីបបរ?

ផន ៖ ស៊ីបបរ ។

ទេវិទ្ធ ៖ ម៉េច ធម្មតា?

ផន ៖ ក្មេងៗ អាណាធ្វើអាចម៍ៗ ធ្វើដីៗនឹងយកទៅដល់ដាក់លាយដាក់អន្ទង់ជ្រុងដីនឹង ។

ទេវិទ្ធ ៖ ថាគេឲ្យភ្លក់មែន ខ្ញុំធ្លាប់សួរគេៗឲ្យភ្លក់?

ផន ៖ ទេ! ពួកនឹងមិនព្រមប្រាប់ខ្ញុំ មិនហ៊ានប្រាប់ក៏មិនដឹង អាខ្លះគេថាឲ្យភ្លក់ ប៉ុន្តែខ្ញុំមិនដែលផង ។

ទេវិទ្ធ ៖ តាដែលឃើញ?

ផន ៖ គ្រាន់តែឲ្យលាយ អត់ ។

ទេវិទ្ធ ៖ ចុះធម្មតាអ្នកធ្វើ?

ផន :	ព្រោះខ្ញុំមិនដែលទៅក្តាប់ផង អាកន្លែងធ្វើបន្លែ ធ្វើព្រៃ ខ្ញុំនៅក្តាប់នៅនឹងភូមិ ។

ទេវិទ្ធ :	គេឲ្យមើលតែភូមិទេ?

ផន :	អឺ! មើលតែភូមិ ដល់បញ្ជូនពួកនឹងទៅ ខ្ញុំបញ្ជូនទៅ ។

ទេវិទ្ធ :	ថាត្រូវការប៉ុន្មាន កម្លាំងប៉ុន្មាន?

ផន :	អឺ!ប៉ុន្មាននាក់ ស្រីប៉ុន្មានប្រុសប៉ុន្មាន អូ!ពិនិត្យមាំណាស់ រឿងទៅនឹងតាមរយៈអីខ្វះៗ តិចល្អមកវិញចោលអីណាអត់បាន ។

ទេវិទ្ធ :	ចុះពេលដែលគេត្រូវយកទៅយ៉ាងម៉េច អ្នកណាគេអ្នកមកយកទៅវត្តប្រធាតុនឹង?

ផន :	ប្រធាតុនឹងឈ្លបគេ ។

ទេវិទ្ធ :	ឈ្លបគេមក?

ផន :	ប៉ូលីសគេ នគរបាលគេ គេមកយកកណ្តាលយប់ក៏បានថ្ងៃក៏បាន គេមកយកស្រេចចិត្តគេ ។

ទេវិទ្ធ :	គាដែលឃើញដែរ?

ផន :	ឃើញតើយកក្រុមគេ ក្រុមខ្ញុំយកបានទៅបាន២ ហើយ១ តែមិនយកដល់នឹងទេ យកដាក់ត្រឹមអន្លុងនាម ហើយដល់គេយកពីអន្លុងនាមទៅ វត្តអន្លុងនាមទៅ គេយកទៅវៃចោលណាទៀតទៅ ។

ទេវិទ្ធ :	ចុះអន្លុងនាមនឹងអីគេ?

ផន :	អន្លុងនាមមានដាក់ទ័ពអីនឹង ដាក់ឯវត្តនោះ ។

ទេវិទ្ធ :	មន្ទីរដែរ?

ផន :	អឺ!

ទេវិទ្ធ :	មន្ទីរដែរ?

ផន :	អត់មានមន្ទីរគេ អន្លុងនាម ។

ទេវិទ្ធ :	អានឹងកន្លែងអីគេ?

ផន :	គ្រាន់កន្លែងនគរបាល ឈ្លបគេ ។

ទេវិទ្ធ :	កន្លែងឈ្លប ស្នាក់ការឈ្លបគេ?

ផន :	អឺ! ស្នាក់ការឈ្លប ។

ទេវិទ្ធ :	អីចឹងគេយកទៅដាក់នៅស្នាក់ការនឹងរួច បានគេបញ្ជូនទៅ?

ផន :	ដាក់នៅនឹងឲ្យឈ្លប អឺ!ដាក់នៅនឹងទៅ ត្រួតត្រាមើលការខុសត្រូវអី ថាអានឹងម៉េចៗបានគេបញ្ជូនទៅបញ្ចប់នៅវត្តប្រធាតុ បើគេយកទៅវៃចោលក៏យកពីនឹងដែរ ។

ទេវិទ្ធ ៖ តាមានដែលទៅដល់នឹងសម័យនឹង?

ផន ៖ ទៅ តាមពួកនឹងគេយកទៅដាក់គុកនឹង ទៅបានមួងដែរ ។

ទេវិទ្ធ ៖ ទៅបានមួង?

ផន ៖ ទៅឃើញតែគ្នាឯងនឹង មើលទៅលំបាកពេក អាណិតវាៗឲ្យទៅមើល ។

ទេវិទ្ធ ៖ តាទៅនឹងប្រហែលឆ្នាំណា?

ផន ៖ ទៅមើល៧៥ ៧៦ ទៅឆ្នាំ៧៦ ។

ទេវិទ្ធ ៖ អូ! ៧៦?

ផន ៖ អឺ! ចុះបែកភ្នំពេញមិន៧៥ យកពួកនឹងគេធ្វើទុកអាមុនដំបូង គេធ្វើខ្លាំងអាមុនដំបូងហើយ ។

ទេវិទ្ធ ៖ តាកាលនឹងម៉េចបានទៅ?

ផន ៖ បានទៅហើយ អានឹងគេចំហឲ្យទៅមើល ។

ទេវិទ្ធ ៖ ទៅឃើញអីខ្លះកាលនឹង?

ផន ៖ ឃើញៗតែអានឹងនៅជាប់គុកនឹង វាមិនទាន់មានវ៉ៃចោល ។

ទេវិទ្ធ ៖ គុកគេនឹងម៉េច ប៉ុនណា?

ផន ៖ គុកនឹងសាលាលោកនឹង សាលាថ្មវែងនៅនឹងដីនឹង ហើយខ្នោះគេៗដាក់តម្រាបទៅអីចឹង ។

ទេវិទ្ធ ៖ ធំទេសាលាលោកនឹង?

ផន ៖ តូច ខ្នោះគេ ។

ទេវិទ្ធ ៖ សាលាលោក?

ផន ៖ ទេ! សាលា កាលនឹងវត្តនឹងមានសាលាណាធំ សាលាតូច សាលាថ្ម ឃើញចំហធ្លុង ។

ទេវិទ្ធ ៖ ប្រហែលប៉ុន្មានម៉ែត្រ?

ផន ៖ បណ្តោយប្រហែលជាង១០ម៉ែត្រ ។

ទេវិទ្ធ ៖ ជាង១០ម៉ែត្រ ទទឹង?

ផន ៖ ទទឹង៦ម៉ែត្រ ។

ទេវិទ្ធ ៖ ដល់ពេលយើងដាក់នឹង ដាក់ប៉ុន្មាននាក់ដែរ ដែលតាទៅឃើញ?

ផន ៖ ទៅឃើញប្រហែលជា៥០នាក់ ។

ទេវិទ្ធ ៖ ៥០នាក់?

ផន ៖ ហើយដល់ដាក់អីចឹងទៅ ។

ទេវិទ្ធ ៖ គេដាក់យ៉ាងម៉េច តាបន្លាញបាន?

ផន ៖ ដាក់ជើង ។

ទេវិទ្ធ ៖ ជើងគេធ្វើម៉េច?

ផន ៖ កងគេ ។

ទេវិទ្ធ ៖ គេមានកងគេ?

ផន ៖ កងគេមូលៗអីចឹង ហើយគេឲ្យយើងដាក់ជើងយើងទៅ ហើយអាកងនឹង ដល់ហើយគេមានរន្ធរនុកដែកដូចខ្នាំងអំពៅ ។

ទេវិទ្ធ ៖ គេអន្ទុយជាប់ៗគ្នា?

ផន ៖ អឺ! ហើយគេឲ្យដាក់ជើងយើងទៅ អន្ទុយជាប់គ្នាតម្រាបប្រិប ដល់ហើយគេយករនុកនឹងបុកប្រាំវមកអីចឹងផុត ហើយមានទៅរត់ណា ដែកមូលចេះៗយកមកដល់គេរឹបជាប់ប្រិបទៅអាណាជើងធំវាតឹងនៅកប់នឹងស្រែកម៉េចស្រែក ។

ធីតា៖ តម្រាបជួរគ្នាម៉ង?

ផន ៖ អឺ!តម្រាបជួរគ្នា២ជួរ ៣ជួរ អាម៉ាជួរនេះម៉ាជួរនោះទល់មុខគ្នាចេះ សណ្ដូកជើងទៅគេដាក់ខ្នោះនៅនឹង ។

ទេវិទ្ធ ៖ ស្រីផ្សេង ប្រុសផ្សេង ហើយយ៉ាងម៉េចតា?

ផន ៖ មិនទេ ដាក់លាយគ្នា ។

ទេវិទ្ធ ៖ អ្នកទោសនឹងស្លៀកខោអាវសមរម្យ?

ផន ៖ ខោអាវយើងធម្មតា ។

ទេវិទ្ធ ៖ ខោអាវខ្មៅនឹង?

ផន ៖ ខោអាវខ្មៅ អាខ្លះអាវខ្មៅ អាវក្រហម យើងស្លៀកម៉េចយកទៅអីចឹង ហើយបើថាពួកវាម៉ងអានឹងថាខោខ្មៅអាវខ្មៅ ។

ទេវិទ្ធ ៖ មេនៅវត្តប្រធានុនឹងឈ្មោះអីគេ ប្រធាននៅនឹង?

ផន ៖ អានេះអានគរបាលគេនឹងឈ្មោះស្អីទេ អាវ៉ៃគេចោល ដល់ហើយគេឲ្យមកលើវិញ កាប់គរម៉ាអន្លង់២០-៣០នាក់ ដល់អានឹងវានៅគេហៅមកលើឲ្យគេបងប្អូនប្រពន្ធកូនគេឲ្យអានឹងមកចុះលើកឲ្យគេ លើកហើយគេស្រង់យកមកនឹងបានក្បាល បានឆ្អឹងនឹងយកមកដាក់នៅវត្តនឹងណា៎ ។

ទេវិទ្ធ ៖ ប្រធាននឹងនៅទៀត?

ផន ៖ ហ្អឹងហើយ ។

ទេវិទ្ធ ៖ ហើយអ្នកមកគាស់នឹងវិញ?

ផន ៖ អឺ! អ្នកវ៉ៃចោលនឹងទៅ ហើយអាអ្នកមិនវ៉ៃចោលគេហៅឲ្យគាស់លើក ។

ទេវិទ្ធ ៖ និយាយប្រធានសន្តិសុខនឹង?

ផន ៖ ហ្នឹង ។

ទេវិទ្ធ ៖ ប្រធានសន្តិសុខនឹងឈ្មោះអីគេ ចាំ រកនឹកបន្តិច?

ផន ៖ កាលនឹងចាំឈ្មោះ ប៉ុនភ្លេចឈ្មោះអានឹង ទេអានឹងវាងាប់បាត់ អាអី អានៅភូមអណ្ដើកនឹងដែរ ភ្លេចឈ្មោះអានឹងហើយ អានឹងគេហៅប្រធាននគរបាលសម្រាប់វ៉ៃមនុស្ស ភ្លេចឈ្មោះអានឹងទៅ ។

ទេវិទ្ធ ៖ តែម្នាក់នឹងទេ ហើយមានអ្នកផ្សេងមកជំនួស?

ផន ៖ ហ៊ើ!មិនម្នាក់ណា ៣-៤នាក់តែវា ប៉ុនវាប្រធាន ។

ទេវិទ្ធ ៖ គេប្រធាន?

ផន ៖ អឺ!

ទេវិទ្ធ ៖ ចុះអ្នកបងប្អូនដែលគេនៅនឹង គេអត់មករករឿងអីទេ?

ផន ៖ ហ៊ើ! អាណាហ៊ាន ។

ទេវិទ្ធ ៖ ក្រោយៗមកទៀត ក្រោយដាច់មក?

ផន ៖ ក្រោយ ចុះអានឹងគ្រាន់ឲ្យលើកមួយ ហើយវារត់ទៅបាត់ទៅ ។

ទេវិទ្ធ ៖ អូ! រត់?

ផន ៖ អឺ! ទៅបាត់វានៅនឹងក៏គេវ៉ៃចោល ។

ទេវិទ្ធ ៖ នៅណាវិញ គាត់រត់ទៅណា?

ផន ៖ ទៅលើ ទៅស្តុកទៅអី មិនដឹងទៅណា ភ្លេចឈ្មោះហើយ ។

ទេវិទ្ធ ៖ ចុះប្រពន្ធកូននៅណា?

ផន ៖ ប្រពន្ធកូនក៏គ្មាននៅនឹងដែរ ។

ទេវិទ្ធ ៖ អត់នៅទេ?

ផន ៖ អឺ! វានាំគ្នារត់ទៅបាត់ ។

ទេវិទ្ធ ៖ តាមានស្គាល់ពីណាគេធ្លាប់ធ្វើការនៅនឹង?

ផន ៖ អឺ!ធ្វើនៅនឹង?

ទេវិទ្ធ ៖ បាទ! នៅវត្តប្រធាតុ?

ផន ៖ មិនមែនទេ ពួកនឹងខ្ញុំអត់ស្គាល់ ។

ទេវិទ្ធ ៖ អត់ស្គាល់?

ផន ៖ ច្រើនតែយកពួកខ្ញុំធ្វើការនឹងយកទៅវៃចោលនឹងដែរ ។

ទេវិទ្ធ ៖ ពីណាគេគា នៅនឹង?

ផន ៖ ប្អូនបានរួចមកវិញ ។

ទេវិទ្ធ ៖ អូ! មានអ្នករួចដែរ?

ផន ៖ រួច គេលែងទោសវាល្មមៗ ។

ទេវិទ្ធ ៖ អីចឹងមិនមែននេះទាំងអស់ទេ គេលែងខ្លះដែរ?

ផន ៖ អាខ្លះគេមានទោស អាមូលដ្ឋាននឹង មានទោសលួចកាប់គោស៊ីក៏គេយកមកដាក់នឹងដែរ ។

ទេវិទ្ធ ៖ មានអ្នកលួចកាប់គោ?

ផន ៖ កាប់គោរួមយើងនឹង គោក្នុងភូមិអាសោៗរួចមកវិញ នៅរស់ទល់ឥឡូវ វានៅធ្វើការនៅណា ។

ទេវិទ្ធ ៖ គាត់នៅណា?

ផន ៖ នៅភូមិត្បែងធំ អានឹងក៏គេយកទៅដែរ ហើយគាលីមមួយឆាប់ អាតាំងលីមួយឆាប់ អាទីមួយឆាប់នៅកន្លែងនឹង ។

ទេវិទ្ធ ៖ សុទ្ធតែអ្នកធ្វើការជាមួយតានៅភូមិ?

ផន ៖ អាទីជាមួយខ្ញុំប្រធានភូមិ ។

ទេវិទ្ធ ៖ ប្រធានភូមិមួយគ្នា?

ផន ៖ អឺ! គេប្រធាន ខ្ញុំអនុ ។

ទេវិទ្ធ ៖ តាអនុ?

ផន ៖ អាទីនឹងវាដឹកនាំគេចូលដៃចូលជើង វាខូចហើយចាប់គេ ដល់ហើយគេយកទៅ យកអាទីនឹងទៅដាក់គុកនៅនឹង ។

ទេវិទ្ធ ៖ អ្នកណាគេអ្នកមកចាប់?

ផន ៖ ពួកនឹង ទេ!ពួកនឹងអីពួកឃុំយើង អាធ្វើឃុំនឹងកូនចៅតាង៉ែតនឹង ឈ្លបតាង៉ែតនឹង ។

ទេវិទ្ធ ៖ ចាប់យកទៅ?

ផន ៖ ចាប់យកទៅដាក់រទេះសេះដឹកទៅ ពេលដល់បញ្ចូលគុកនឹង ពេលឆាប់ៗនឹងគុកនឹង ។

ទេវិទ្ធ : ចុះអ្នកដែលគេប្រើ អ្នកណាអ្នកប្រើតាថាឲ្យធ្វើនេះធ្វើនោះ ត្រូវចាត់ចែងទៅនេះទៅនោះ អ្នកណាគេអ្នកប្រាប់?

ជន : អ្នកចាត់ចែងទៅធ្វើការឯណា ទៅដើរធ្វើប្រឡាយអី?

ទេវិទ្ធ : បាទៗ ។

ជន : អានឹងតាង៉ែតនឹង ។

ទេវិទ្ធ : តាង៉ែតណា?

ជន : តាង៉ែតប្រធានឃុំនឹង ។

ទេវិទ្ធ : ចុះអ្នកណាតពីឃុំនឹងទៅទៀត?

ជន : តនឹងមានតាអុង ។

ទេវិទ្ធ : តាអុងនឹងពីណាគេ?

ជន : នៅភូមដណ្ដើម ។

ទេវិទ្ធ : គាត់ធ្វើអីគេ?

ជន : គាត់ធ្វើយោធាៗខាងឃុំ ។

ទេវិទ្ធ : ប្រធានឃុំ?

ជន : អឺ!

ទេវិទ្ធ : ចុះអ្នកណាដូចថាបញ្ជាពីលើឃុំទៀត?

ជន : ពីលើឃុំមានតាដុំ ។

ទេវិទ្ធ : តាដុំនឹងពីណាគេ?

ជន : តាដុំនឹងមនុស្សពីលើមក ។

ទេវិទ្ធ : អត់ដឹងគាត់ពីណា?

ជន : ចៅហ្វាយស្រុក ។

ទេវិទ្ធ : គាត់ចៅហ្វាយស្រុក?

ជន : មកពីដំណាក់ស្នួល ។

ទេវិទ្ធ : ឥឡូវគាត់នៅណា ដឹងទេតា?

ជន : ទេ! ឥឡូវបាត់ តាំងពីបែកមិនដឹងនៅណា ។

ទេវិទ្ធ : អត់ដឹង?

ផន ៖ កាលនឹងគាត់ធ្វើចៅហ្វាយស្រុកនៅនឹង ហើយយាយបូ ២នាក់យាយបូស្រី អានឹងគេចៅហ្វាយស្រុកគេដែរ ។ អត់ពី មើលតាតឿន១ ដុំ ហើយយាយបូ ៣នាក់សមាជិកគេ អនុប្រធានគេ ។ ហើយអត់ពីតាដុំនឹងទៅបាត់ទៅ តាតុំមិនមែនតាដុំទេ ដល់អីចឹងនៅយាយបូវិញ ។ អានឹងខ្ញុំសរុប...គេផ្លាស់ខ្ញុំនៅនឹង ។ អីចឹងគេដកពីនឹងហើយដកពី១៧នឹង បញ្ជូន១៧ ដល់ខ្ញុំបានម៉ាកំណាត់ គេបញ្ជូន១៧ឡើងទៅលើអស់លើងបញ្ជូនទៅទាំងអស់ ខាងកំពង់សោមក៏យកទៅនោះ ភ្នំពេញក៏ទៅនោះ ។

ទេវិទ្ធ ៖ ប្រហែលយកឆ្នាំណា?

ផន ៖ យកទៅមើល ៧៧ ។

ទេវិទ្ធ ៖ ចុះអ្នកដែលនៅសល់ភូមិនេះ មានអ្នកមកទៀតទេ មានអ្នកមកថ្មី?

ផន ៖ គ្មាន ។

ទេវិទ្ធ ៖ នៅតែអ្នកមូលដ្ឋានទាំងអស់?

ផន ៖ អឺ!

ទេវិទ្ធ ៖ ក្រោយ៧៧អស់អ្នកថ្មីហើយ?

ផន ៖ អស់អ្នកថ្មីលើង ។

ទេវិទ្ធ ៖ គេបញ្ជូនទៅណាវិញ អ្នកថ្មីនឹង?

ផន ៖ ទៅស្រុកគេទៅ ទៅបញ្ជូនទៅលើដល់មកវិញគេទៅនៅតាមស្រុកគេវិញ ដល់បែក ។

ទេវិទ្ធ ៖ អស់ម៉ង់ពីភូមិតា?

ផន ៖ អស់លើងគ្មាននៅមួយទេ ។

ទេវិទ្ធ ៖ ចុះការហូបចុកអីយ៉ាងម៉េច ពីការហូបចុករបស់អ្នកថ្មីទាំងអស់នឹងយ៉ាងម៉េច?

ផន ៖ ហូប១ពោតសំឡី ។

ទេវិទ្ធ ៖ ឆ្អែត?

ផន ៖ មិនឆ្អែត ។

ទេវិទ្ធ ៖ មានអ្នកដាច់ពោះស្លាប់?

ផន ៖ អត់ទេ អត់មានអីចឹងទេ គ្រាន់វាមិនបានបរិបូណ៌ ហូបអាចំណីពោតសំឡីយកមកស្ងោរ ហើយនឹងបបរនឹង ហូបតែ២មុខ ។

ទេវិទ្ធ ៖ ស្រូវអីធ្វើបានច្រើន?

ផន ៖ ស្រូវធ្វើបានក្រែល១ យកដាក់... ។

ទេវិទ្ធ :	ប៉ុន្តែស្រូវអស់នឹងយើងយកមកហូប ផ្គត់ផ្គង់ក្នុងភូមិយើង ឬមួយយកទៅណា?

ផន :	ស្រូវៗនឹងតាមភូមិៗណាធ្វើបានប៉ុន្មានគេដាក់ស្រង់អីចឹងទៅ ប៉ុនភូមិណាដើរចល័ត ដើរធ្វើការព្រៃទៅដល់ភ្នាស់ទៅដល់ទៅហូបបាយនឹងទៅ។ ត្រង់ៗមានដូចគ្នា ដូចម្តេចត្រង់រួម ទៅណាស៊ីនឹងបាន ហើយម្ហូមក្រោលគោ ក្រោលជ្រូកគេ យើងថាឥឡូវគ្មានម្ហូបទាញអាជ្រូកក្រោលគេនឹងមក យកមកកាប់ស៊ីទៅចែកសមាជិកយើង។

ទេវិទ្ធ :	ចុះស្រូវគេមានបញ្ជូនទៅលើ?

ផន :	គ្មានទេ។

ទេវិទ្ធ :	ស្រូវធ្វើបានហូបតែភូមិយើង?

ផន :	ហ្នឹងហើយ គ្មានបញ្ជូនទៅណាស្រូវតាមពិត។

ទេវិទ្ធ :	ឃុំគេអត់មកយកតំរូវយកស្រូវពីយើង?

ផន :	អត់ទេ មិនយកទេ ស្រូវភូមិណាភូមិនឹងយកហូបទៅ គេប្រគល់ឲ្យប្រធានភូមិនឹងចាត់ចែងមេឃុំជាប្រធាន។ ប៉ុនតាមខ្ញុំគិតទៅ ដល់មែនទែន ដល់ទីបញ្ចប់ គឺអង្គរអីមកបើកពីឃុំនឹងទៅវិញ យើងនឹងគេផ្តាច់ហើយ គេផ្តាច់លែងឲ្យមានធ្វើតាមភូមិ។

ទេវិទ្ធ :	លែងឲ្យធ្វើស្រែម៉ង?

ផន :	ធ្វើៗប៉ុនគេធ្វើរបស់គេ ប៉ុនគ្រាន់យកកម្លាំងយើងទៅធ្វើ ស្រូវនឹងនៅឃុំ។

ទេវិទ្ធ :	ឆ្នាំណាដែរ ចាប់ផ្តើមធ្វើអីចឹង?

ផន :	ធ្វើអីចឹង ចាំមើល៧៥វាបែងនោះ ៧៦នៅក្រុមល្អិតទេ ៧៧ៗអានឹងគេប្រមូលរួមអស់ហើយ។

ទេវិទ្ធ :	អីចឹងគេចាប់ផ្តើមធ្វើរួម?

ផន :	អឺ! ធ្វើរួម បាយរួម កាល៧៦បាយតាម។

ទេវិទ្ធ :	ផ្ទះ?

ផន :	តាមភូមិតាមក្រុម។

ទេវិទ្ធ :	អូ! អានឹងគេហៅចូលដល់សហករណ៍ជាន់ខ្ពស់?

ផន :	ហ្នឹងហើយ។

ទេវិទ្ធ :	សហករណ៍ជាន់ខ្ពស់ គឺគេដាក់រួមដាក់អីទាំងអស់?

ផន :	ដាក់រួមទាំងអស់ ឧបមាថាប្រមូលតាំងពីចាន តាំងពីឆ្នាំងអីអស់រលីង ខ្ញុំទៅនៅកង.... មិនប្រមូលតែពួក១៧ ចានឆ្នាំងប្រមូលពីអ្នកមូលដ្ឋាន ដល់១៧គេបញ្ជូនទៅលើនៅតែខ្ញុំមូល

ដ្ឋាន គេប្រមូលបានឆ្នាំងដាក់តាមរោងបាយគេទាំងអស់។ ប្រធានភូមិណាចិត្តល្អទៅគេទុកឲ្យ ឆ្នាំង១ បានមួយសម្រាប់ហូប ដូចខ្ញុំមានទុកឲ្យ។

ទេវិទ្ធ : ដល់ពេលគេចាប់ផ្ដើមធ្វើរួមមក ឃុំគេកាន់កាប់ស្រូវទាំងអស់?

ផន : ស្រូវនៅលើគេ គេធ្វើដើរធ្វើនៅភូមិណា ក៏ស្រូវនៅលើគេ ប៉ុនស្រូវនឹងបើតាមគិតទៅគ្មាន ប្រមូលទុកថាសម្រាប់ឲ្យមកផ្គត់ផ្គង់ប្រជាជនទេ ស្រូវនឹងបែកឃើញដឹកទៅណាទៀត។

ទេវិទ្ធ : បើតាមតាពិនិត្យមើលទៅធនធានស្រូវនឹង យើងធ្វើបានច្រើនទេ ស្រូវ?

ផន : អឺ! ធ្វើមិនសូវបាន។

ទេវិទ្ធ : ធ្វើអត់សូវបាន?

ផន : ម៉េចអីចឹង ហើយវាប្រើដីនេះ គេប្រើដីធម្មជាតិ ហើយវាផ្សំដីធ្វើប៉ាចស្រូវទៅ បើធ្វើទៅ ធ្វើបានតិចតួច។

ទេវិទ្ធ : ធ្វើបានតិចតួចទេ?

ផន : អឺ! តែអានឹងគេដាក់...រួមនៅនឹងឃុំហើយ គេធ្វើធំណាស់។ ហើយដល់នេះគេហៅប្រធាន ភូមិមកបើកស្រូវបើកអង្ករអី អង្ករគេកិន ថាមកបើកប៉ុន្មានថ្ងៃបើកម្ដង គេឲ្យម៉ាភូមិ២ បាវ១ អង្ករ។

ទេវិទ្ធ : ម៉ាភូមិ២បាវ?

ផន : ២បាវអង្ករ។

ទេវិទ្ធ : រយៈពេលប៉ុន្មាន?

ផន : ៥ថ្ងៃ ៦ថ្ងៃ។

ទេវិទ្ធ : ៥ថ្ងៃ ៦ថ្ងៃ ២បាវស៊ីម៉ាភូមិ មនុស្សរាប់រយនាក់?

ផន : អឺ!ចុះបបរម៉ាខ្ទះ៧កំប៉ុង បបរទឹកនឹង។

ទេវិទ្ធ : អីចឹងភូមិបើកអង្ករពីឃុំ?

ផន : បើកពីឃុំ មិនម្ហូបនៅលើឃុំគេបើកទាំងអស់។

ទេវិទ្ធ : ចុះកាលនឹងម៉េចបានយើងអត់មានអី ម្ហូបអីយ៉ាងម៉េចដែរ?

ផន : ម្ហូបដោះស្រាយខ្លួនយើងតាមភូមិ គោយើង ជ្រូកយើងចិញ្ចឹម យើងកាប់ស៊ីទៅ។

ទេវិទ្ធ : ម៉ាឃុំនេះសហករណ៍ប៉ុន្មាន សហករណ៍?

ផន : ទេ! ច្រើន។

ទេវិទ្ធ : ច្រើនសហករណ៍ដែរ?

ផន :	ប៉ុន្មានដណ្ដប់សហករណ៍ មានភ្នាស់ ទួលរកា កកោះ ស្វាយជ្រុំ ភ្នំរន្ទះ ១២សហករណ៍ ។

ទេវិទ្ធ :	ម៉ាឃុំ?

ផន :	អឺ!

ទេវិទ្ធ :	មានន័យថាម៉ាភូមិប៉ុន្មានសហករណ៍?

ផន :	ម៉ាភូមិវានិយាយម៉ាភូមិ មានតែ៥សហករណ៍ទេ ។

ទេវិទ្ធ :	ម៉ាភូមិច្រើនម៉េច?

ផន :	ច្រើនម៉េច ភូមិឡើងភូមិមួយៗ មើលនៅនឹងហើយនឹងស្វាយជ្រុំបញ្ចូលគ្នាទាំងអស់ អានឹងធ្វើប្រធានភូមិតែមួយ ។

ទេវិទ្ធ :	អីចឹងមានន័យថាសហករណ៍តែមួយទេ ២ភូមិនឹង?

ផន :	ហ្នឹងហើយតែមួយ ។

ទេវិទ្ធ :	អីចឹងម៉ាឃុំនឹងអាចប៉ុន្មានសហករណ៍?

ផន :	ម៉ាឃុំនឹងច្រើនណាស់ ។

ទេវិទ្ធ :	នៅឃុំអង្គប្រាសាទនេះ?

ផន :	មើលម៉ាភូមិខ្ញុំនឹងគិតទៅ បើតាមគិតទៅមើលសហករណ៍នេះ១ ស្វាយធំ១ ភ្នំរន្ទះនឹង៣ភូមិ ខ្ញុំតែ៣នឹង ។

ទេវិទ្ធ :	៣សហករណ៍ម៉ាភូមិនេះ?

ផន :	ត្រង់នឹង២ ទេ!ត្រង់នឹងតែមួយទេម៉ាសហករណ៍ ។

ទេវិទ្ធ :	ម៉ាសហករណ៍ទេ?

ផន :	ភូមិខ្ញុំជាប់គ្នា ហើយដូចស្វាយធំនឹងម៉ាសហករណ៍ដែរ ។

ទេវិទ្ធ :	ប្រធានភូមិនឹង ប្រធានសហករណ៍នឹងតែមួយ?

ផន :	អឺ! តែមួយនឹង ប្រធានភូមិប្រធានសហករណ៍ ។

ទេវិទ្ធ :	ចុះតាពេលដែល និយាយរឿងត្រឹមឆ្នាំ៧៧សិន នៅពេលដែលគេបញ្ជូនប្រជាជនថ្មីអស់ចេញពីភូមិនេះទៅ សហករណ៍យើងនៅដដែល?

ផន :	នៅដដែល ។

ទេវិទ្ធ :	ចុះមិនខ្វះមនុស្សទេ បើដូនទៅអស់ហើយ?

ផន :	មិនខ្វះទេ អានឹងមូលដ្ឋានគេមានរបស់គេហើយ ។

ទេវិទ្ធ :	អ្នកមូលដ្ឋាននៅខ្វះដែរ?

ផន ៖ អឺ! នៅ ។

ទេវិទ្ធ ៖ ចុះដកចេញអស់៤៥នាក់?

ផន ៖ ឧបមាថាឥឡូវយើងមូលដ្ឋាននេះយើង៤០គ្រួសារ
ដកបញ្ចូលពួក១៧មក៤០នឹងទៅវាឡើង ៨០ ហើយដល់ដកពួកនេះអស់៤០ទៅ វានៅពួកនេះ៤០ដដែល ។

ទេវិទ្ធ ៖ នៅធ្វើការធម្មតាអីចឹងទៅ?

ផន ៖ អឺ! ធម្មតា ប៉ុនបបរអីដូចគ្នា ។

ទេវិទ្ធ ៖ អត់លើសគ្នា?

ផន ៖ គេធ្វើអត់លើសគ្នាកើត លើសមានគំនិតលាក់លាមអានឹងមាន ។

ទេវិទ្ធ ៖ ចុះតា ប្រជាជនគេចែកគ្នាប៉ុន្មានប្រភេទ មានអ្នកគេចែកជាប៉ុន្មានប្រភេទ?

ផន ៖ ចែកជា២ប្រភេទ ។

ទេវិទ្ធ ៖ អ្នកចាស់ អ្នកថ្មី?

ផន ៖ អឺ!

ទេវិទ្ធ ៖ ចុះមានអ្នកពេញសិទ្ធិ អ្នកត្រៀម អ្នកបញ្ញើអី?

ផន ៖ អឺ! អានឹង២ ។ ទៀតវាមាន៤នឹងគេ ។

ទេវិទ្ធ ៖ អ្នកពេញសិទ្ធិ អ្នកយ៉ាងម៉េច?

ផន ៖ ពេញសិទ្ធិដែលគេអត់មានហៅមូលដ្ឋាននឹង គេអត់មានពាក់ព័ន្ធទៅលើអីណា ពាក់ព័ន្ធបងប្អូនណាធ្វើការងារនៅភ្នំពេញនៅអី អានឹងគេពេញសិទ្ធិគេហើយ ។

ទេវិទ្ធ ៖ ចុះអ្នក១ ?

ផន ៖ នៅភ្នំពេញ អានឹងមកពីបងប្អូនយើង១៧ផង បងប្អូនយើងនៅធ្វើការនៅឯណា១ អានឹងអត់ពេញសិទ្ធិទេ ។

ទេវិទ្ធ ៖ អានឹងគេហៅអី អ្នកត្រៀម អ្នកអី?

ផន ៖ អ្នកត្រៀម ។

ទេវិទ្ធ ៖ ហើយចុះមួយទៀត?

ផន ៖ អ្នកផ្ញើ ។

ទេវិទ្ធ ៖ អ្នកផ្ញើនឹងយ៉ាងម៉េច?

ផន ៖ ផ្ញើនឹងអានឹងគ្រាន់ផ្ញើដូចពួកនេះ ពួកភ្នំពេញមកគេហៅអ្នកផ្ញើ ។

ទេវិទ្ធ : អ្នកបញ្ញើយ៉ាងម៉េច?

ផន : អ្នកបញ្ញើនឹងដូចថាមកនៅបណ្ដោះអាសន្នសិន ដើម្បីថាគេថាអានឹងគេផ្ញើសិន យើងនៅរស់ដោយសារផ្ញើនឹង អានឹងដូចថាផ្ញើ ត្រៀម ហើយនឹងពេញសិទ្ធិ ។

ទេវិទ្ធ : អីចឹងដូចអ្នក១៧នៅភូមិតា ត្រូវគេបញ្ជូនទៅរស់នៅនៅបាន២ឆ្នាំ ទៅគេបញ្ជូនទៅរស់ ផ្ញើរបៀបអីចឹង?

ផន : បាទ! អានឹងអីចឹង គេផ្ញើសម្រាប់បញ្ជូនទៅទៀត ។

ទេវិទ្ធ : ចុះរបបអាហារវិញយ៉ាងម៉េចដែរ ដូចថាអ្នកពេញសិទ្ធិបានច្រើនជាង អ្នកត្រៀមបានតិចយ៉ាងម៉េចដែរ រឿងម្ហូបអាហារ?

ផន : មិនទេ អានឹងអត់មានបែងចែកទេ រឿងហូប យើងផ្ញើដូចគ្នា ។

ទេវិទ្ធ : ញ៉ាំដូចគ្នា?

ផន : អឺ!

ទេវិទ្ធ : ចុះអ្នកពេញសិទ្ធិនឹងយ៉ាងម៉េចដែរ មានអីពិសេសជាងគេបានពេញសិទ្ធិ បានគេឲ្យឈ្មោះ?

ផន : ពេញសិទ្ធិនឹង ថាគេល្អជាងគេ គេអត់មានធ្វើការងារអី គេអត់មានពាក់ព័ន្ធទៅលើអីៗទាហានអី អានឹងគេពេញមុនគេ ។ យើងមូលដ្ឋាននឹងក៏ដោយ យើងមិនធ្លាប់ធ្វើទាហានធ្វើអីអានឹងគេហៅពេញសិទ្ធិ ។ មូលដ្ឋាននឹងមានបងប្អូនធ្វើទាហាន គេយកប្ដីវៃចោលអស់ទៅនៅតែប្រពន្ធ នាងនុបនឹងម៉េមាយ អីចឹងទាំងអស់ ហើយអានឹងម៉េចនឹងពេញសិទ្ធិ ។

ទេវិទ្ធ : ចុះអ្នកត្រៀម អាចក្លាយជាអ្នកពេញសិទ្ធិវិញទេ?

ផន : ថីមិនក្លាយ ។

ទេវិទ្ធ : អាចដែរ?

ផន : បាទ! អាចទៅពេញសិទ្ធិវិញ បើយើងត្រៀម គេឲ្យយើងត្រៀមខ្លួនអីចឹង ដើម្បីឲ្យយើងធ្វើការនឹងវាស្អាត អត់មានធ្វើនយោបាយត្រឹមត្រូវ អានឹងចូលទៅពេញវិញ ។

ទេវិទ្ធ : អីចឹង?

ផន : បាទ! យើងអត់មានធ្វើនយោបាយបំផុសបំផុលអីនឹង ។

ទេវិទ្ធ : ចុះអ្នកណាជាអ្នកសម្រេចថាអ្នកនឹងអាចឡើងពេញសិទ្ធិ អ្នកណាអាច?

ផន : ពេញសិទ្ធិមកពីទៅពីប្រធានភូមិទៅឃុំ ។

ទេវិទ្ធ : អីចឹង?

ផន : ភូមិគេប្រាប់ថាអ្នកនេះធ្វើការស្អាតត្រឹមត្រូវចេះចោះ អត់មានធ្វើនយោបាយ អានឹងពេញសិទ្ធិហើយ ប្រាប់ទៅឃុំណា រឿងតែប៉ុននឹង។ តែមិនពេញសិទ្ធិ យើងធ្វើការមិនកើត យើងនឹងវាក្សត់នឹងគេ យើងមកធ្វើនយោបាយចេះចោះ បំផុសបំផុលចេះចោះ អានឹងគេថាអត់ពេញសិទ្ធិ។

ទេវិទ្ធ : ចុះភាគច្រើនអ្នកគេយកទៅ យកអ្នកណាទៅ? អ្នកដែលគេយកទៅវត្តប្រធាតុនឹង?

ផន : យកវត្តប្រធាតុនឹងតែឈ្លបឃុំគេម៉ង ពួកយោធាឃុំគេ ឈ្លបឃុំចំម៉ង។

ទេវិទ្ធ : ឈ្លបឃុំ?

ផន : អឺ!

ទេវិទ្ធ : មាននៅសល់នៅភូមិឃុំយើងទេ នៅក្បែរៗនេះមានទេ?

ផន : ថីមិនមាន។

ទេវិទ្ធ : មានដែរ ឈ្មោះអីខ្លះ?

ផន : ហេ!ឈ្មោះតានេះនៅនឹងក៏មានមួយដែរ ហួច ដែលកើត អាទី អាអង់នៅភូមិជើងចេះនៅ។

ទេវិទ្ធ : ចុះពេលដាច់ចូលមកវិញ គេឃុំភូមិគេអត់ធ្វើអី?

ផន : ទេ! អ្នកស្រុកភូមិនឹងគេស្អប់ដែរ គេខឹងដែរ កាលយើងធ្វើឈ្លបនឹង យើងចេះដើរចាប់ប្រធានចាប់អីចឹងណា។

ទេវិទ្ធ : ចុះតាពេលដាច់៧៩ទៅ តានៅណា?

ផន : ៧៩ ខ្ញុំនៅនឹង។

ទេវិទ្ធ : នៅនឹងម៉ង?

ផន : អឺ!

ទេវិទ្ធ : ចុះប្រជាជនអីគេយ៉ាងម៉េចដែរ គេអត់មានខឹងសម្បារយើង?

ផន : អត់ទេ ខ្ញុំធ្វើនៅនឹងហើយ គេបញ្ជូនទៅក្ដាប់ឯងកោះកុសលទៀត នៅភូមិនឹងទៀត គេផ្លាស់សុទ្ធតែផ្លាស់អីចឹង ឧបមាថាឥឡូវស្វាយធំផ្លាស់ទៅនៅវត្តស្វាយ ភ្នំរន្ទះផ្លាស់ទៅនៅគោករកា ហើយខ្ញុំពីនេះទៅគេឲ្យទៅនៅក្ដាប់កោះកុសល។

ទេវិទ្ធ : កោះកុសល?

ផន : កោះកុសល អាភូមិទៅពីគោករកាទៅខាងលិចនឹង។

ទេវិទ្ធ : ប៉ុន្តែនៅនឹងជា?

ផន ៖ គេឲ្យទៅក្តាប់នៅនឹង ។

ទេវិទ្ធ ៖ ឆ្នាំណាដែរ?

ផន ៖ ចេញទៅក្តាប់នៅគោករកានឹង ៧៧ ។

ទេវិទ្ធ ៖ ៧៧ពេលគេដកប្រជាជនថ្មីចេញនឹង?

ផន ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ ទៅដំណាលគ្នាដែរ?

ផន ៖ ទៅដំណាលគ្នា ដកពួកនឹងទៅ ដកពួកខ្ញុំនេះផ្លាស់ទៅនោះ ផ្លាស់គ្រប់ភូមិទាំងអស់ ដូរគ្នាឲ្យធ្វើការ គេហៅថាលំអិត ។

ទេវិទ្ធ ៖ ចុះទៅគោករកានោះមានប៉ុន្មាន ទៅកាន់សហករណ៍ដដែល?

ផន ៖ សហករណ៍ដដែល យើងធ្វើប្រធានភូមិដដែល យើងនៅក្តាប់គេនឹង ។

ទេវិទ្ធ ៖ ប៉ុន្មានគ្រួសារដែរ មានអ្នកថ្មី?

ផន ៖ អត់ទេ អានឹងបញ្ជូនថ្មីអស់ ។

ទេវិទ្ធ ៖ អ្នកថ្មីបញ្ជូនទៅអស់ដែរ នៅគោករកានឹង?

ផន ៖ បញ្ជូនទៅអស់ អ្នកណាក៏បញ្ជូនទៅអស់ មាសក៏អស់ បានគេដកពួកយើង ។

ទេវិទ្ធ ៖ អ្នកណាគេអ្នកប្រាប់មកឲ្យបញ្ជូនអ្នកថ្មីទៅ?

ផន ៖ ទេ! អានឹងពីស្រុកមក ពីថ្នាក់លើ ។

ទេវិទ្ធ ៖ ស្រុកមកថ្នាក់មកខាងណាទៀត អ្នកណាអ្នកប្រាប់តា?

ផន ៖ នៅលើឃុំ ។

ទេវិទ្ធ ៖ មកឃុំ?

ផន ៖ អឺ! ឃុំគេនឹងតាង៉ែត ។

ទេវិទ្ធ ៖ តាង៉ែតនឹងប្រាប់មកអ្នកណាគេ?

ផន ៖ ប្រាប់ប្រធានភូមិ ។

ទេវិទ្ធ ៖ ប្រាប់ប្រធានភូមិ?

ផន ៖ ប្រាប់ថាឥឡូវថ្ងៃនេះៗត្រូវដកពួកនឹងទៅនេះ គេឲ្យប្រមូលមួយដុំប្រមូលនៅវត្ត ដល់ហើយបានឡានគេមកយកទៅ ។

ទេវិទ្ធ ៖ អត់ដឹងទៅ?

ផន ៖ មិនដឹងទៅណា ទៅនៅដល់ស្រែអណ្ដូងៗឃុំសំឡាញនោះ ទៅនៅនឹងទាំងអស់ ខ្លះទៅនៅត្រាំកក់ ពួកនឹងមកវិញ មកជួបខ្ញុំវិញដែរ ។ ដល់បែកទៅបានមក មានខូចខាតដែរ ពួកនឹងទៅពីនេះទៅអត់ទេ ទៅពីភូមិខ្ញុំនៅទាំងអស់ ។ ទៅនឹងមើលខ្ញុំប្រាប់ ខ្ញុំថា«ឥឡូវនឹងសាច់ជ្រូកគេចំរាញ់យកសុទ្ធតែខ្លាញ់ហើយៗ បងប្អូនទៅនឹងឲ្យប្រយ័ត្នទ្រាំទៅ ទ្រាំអត់ទ្រាំឃ្លានទៅ ។

ទេវិទ្ធ ៖ តាប្រាប់គេ?

ផន ៖ ប្រាប់ បានពួកនឹងវារស់នៅច្រើន បានអាខ្លះគេមិនប្រាប់ទេ ខ្ញុំប្រាប់ ។

ទេវិទ្ធ ៖ ហើយអ្នកទាំងអស់នឹងមក ក្រោយមកអរគុណតាវិញ?

ផន ៖ អឺ! ក្រោយមកបានដឹងអីចឹងបានអរគុណវិញ បាទ!វាដឹងគុណទាំងអស់ ហើយប្រធានភូមិក្រៅពីនឹងអត់ទៅចូលដីនឹងវិញបានទេ នៅក្ដាប់រកទៅវិញមិនបានឲ្យឃើញប្រធានភូមិនឹងគេវ៉ៃជិតាន់នឹង... វាទៅរកត្រីណាបៀតនឹងដើរបៀតភូមិ គេដេញវ៉ៃ អត់ហ៊ានដើរទេ ។ ហើយ ខ្ញុំគ្រាន់បែកមកភ្លាម ទៅដល់គេធ្វើម្ហូបធ្វើអីឲ្យហូបស្រួលបួលដូចអត់នេះ ។

ទេវិទ្ធ ៖ បែកភ្លាមតានៅណា បែកភ្លាមពេលវៀតណាមចូលមក?

ផន ៖ វៀតណាមចូលមករំដោះមក ខ្ញុំមកនៅកើតនោះ គ្មានបាននៅភូមិនឹងទេ ។

ទេវិទ្ធ ៖ ខាងកើតនឹងខាងណាវិញ ភូមិអីគេ?

ផន ៖ ទឹកល្អក់ ។

ទេវិទ្ធ ៖ ទឹកល្អក់?

ផន ៖ ភូមិស្វាយធំដដែល ។ តិចដល់វាចប់ហើយ ប្រធានឃុំតាង៉ែត គេបញ្ជូនរតាត់រតាយទៅលើទៀតទៅ ដល់នេះបានខ្ញុំនៅនេះ មកនៅកំពង់ចាម ។

ទេវិទ្ធ ៖ គេអត់នេះ គេអត់បញ្ជូនយើងនៅពេលវៀតណាមបញ្ជូនមកនឹង គេអត់កៀរយើងទៅ ហៅយើងទៅ ខាងឃុំខាងអីរត់?

ផន ៖ អត់ទេ ។

ទេវិទ្ធ ៖ អត់ទេ?

ផន ៖ ចុះបើគ្នាវារត់ដែរ វៀតណាមមកភូមិនឹងរត់ ។

ទេវិទ្ធ ៖ ចុះតាអត់បានរត់ទេ?

ផន ៖ រត់ជាមួយគ្នាទាំងអស់ ។

ទេវិទ្ធ ៖ រត់ទៅដល់ណាទៅ បានមកវិញ?

ផន ៖ ខ្ញុំកាលនោះគេបញ្ជូនទៅនៅកោះអណ្តែត ទៅនៅធ្វើស្រែនឹង ហើយដល់យួនបុកពីនឹងមក ទ័ពក៏នៅនឹងមេឃុំក៏នៅនឹង ដល់ហើយឡើងមក ឡើងទាំងអស់គ្នាមក ។

ទេវិទ្ធ ៖ ឡើងមកខាងណាវិញ?

ផន ៖ ឡើងមកមិនឡើងនៅនឹងណា ឡើងទៅឆ្ងាយអន្លង់វែង នោះ ។

ទេវិទ្ធ ៖ រត់ទៅអន្លង់វែង?

ផន ៖ អឺ! អានឹងពី៧៩នឹងបានរំដោះបានពីនឹងមកវិញ បានមកនៅនឹង ។

ទេវិទ្ធ ៖ ចុះពេលគេបញ្ជូនគាត់ទៅកោះអីគេ កោះរកា កោះអណ្តែត កោះអីគេ?

ផន ៖ កោះ អឺ!ភូមិកោះកុសល ។

ទេវិទ្ធ ៖ កោះកុសល ៗនឹងគាត់ទៅទាំងគ្រួសារ ទៅទាំងអី?

ផន ៖ ទៅទាំងអស់ ។

ទេវិទ្ធ ៖ ទៅទាំងប្រពន្ធគាត់?

ផន ៖ ដូចថាទៅប្រជាជននេះនៅនេះដដែល គេយកតែខ្ញុំប្រធានភូមិទៅនោះទេ ហើយបងប្អូនខ្ញុំនៅនេះ វាអីចឹងមានតែប៉ុននឹង ។

ទេវិទ្ធ ៖ គាត់ខ្ញុំដូចអត់មានអីសួរគាត់ទៀតទេ ។ ធីតាមានអីចង់សួរបញ្ជាក់គាត់?

ធីតា ៖ លោកតានៅសម័យខ្មែរក្រហមមានស្លាប់បងប្អូននៅសម័យខ្មែរក្រហម?

ផន ៖ ស្លាប់អស់២ ក្មួយខ្ញុំ២ ហើយនឹងកូនខ្ញុំ១ ។

ទេវិទ្ធ ៖ កូនដែលបាត់ខ្លួននឹង?

ផន ៖ អឺ! កូននឹងខ្ញុំដឹងដំណឹងថាកាលមុនបែកនៅភ្នំពេញៗដឹងហើយគេមកប្រាប់ ។

ទេវិទ្ធ ៖ អ្នកណាគេមកប្រាប់?

ផន ៖ ហ៊ុំនឹងនៅភូមិនឹងគេធ្វើទ័ពៗអាពតនឹង ។

ទេវិទ្ធ ៖ គេមកប្រាប់ថាម៉េចដែរ?

ផន ៖ គេថាឃើញកូនតាឯងនៅផ្ទះថ្មនៅលើ វាអើតមកវាឃើញហ៊ុំនឹងទ័ព ហើយវាស្រែកសួរថា "ហ៉េ!ពូៗឯងមកពីណា?" វាសួរថា"ឯងកូនពីណា?" ថា"កូនតាផន ។ អឺ! ផ្តាំទៅម៉ែឪខ្ញុំផង ខ្ញុំនៅនេះទេ" ហើយដល់យួនវាបុកមក ពួកនឹងវារត់ៗតាមទ័ពគ្នាវាអស់ទៅ ។ វាទៅដល់ភ្នំលះបង់ទៅងាប់នឹងអស់ទៅ ដល់ជិតថៃហើយដល់តាមអាមេគេ ។

ទេវិទ្ធ ៖ ថាកូនតានឹង?

ផន ៖ អឺ! ហើយអាប្អូននោះមួយ ក្មួយ១ ប្អូន១ហើយកូនមួយ អស់៣ អានឹងងាប់ជំនាន់ប៉ុលពត នឹងអស់៣ ។

ទេវិទ្ធ ៖ កូនបានឮដំណឹងតែម្ដងនឹងឯង?

ផន ៖ មានម្ដង តាំងពីមិនទាន់បែក ដឹងវានៅ បើវាគេរំដោះអីចឹងកុំរត់ទៅនោះ រត់មកផ្ទះមានអី ។

ទេវិទ្ធ ៖ គាត់រត់ទៅទល់ដែនថៃ?

ផន ៖ អឺ! តែគេរំដោះភ្នំពេញនឹងបាន បើយើងមកជាមួយពួកភ្នំពេញមកក៏រួចខ្លួន ។

ទេវិទ្ធ ៖ ស្ដាយស្រណោះដែរ?

ផន ៖ ហ៉ឹ! មីនោះចេះណាស់ អក្សរក៏ចេះត្រឹមត្រូវបានគេឲ្យវាធ្វើពេទ្យ រៀនថ្នាក់ទី៩ដែរ ។

ទេវិទ្ធ ៖ ធីតាមានអីសួរបញ្ជាក់តាទៀតទេ?

ធីតា ៖ លោកតាទៅវត្តប្រធាតុនឹង លោកតាបានឃើញគេដាក់ឈ្មោះតែម្ដង?

ផន ៖ ទៅមើលបានម្ដង ។

ធីតា ៖ ទៅនឹងកាលឆ្នាំណា?

ផន ៖ អត់ទេ ទៅនឹងកាលគេចាប់យកពួកនឹងទៅ តាំងពី៧៦ចប់ ៧៧ ។

ទេវិទ្ធ ៖ ៧០ប៉ុន្មានច្បាស់ តាប្រាប់ខ្ញុំដំបូង៧៦?

ផន ៖ អឺ! ៧៦នឹងក៏វាជិតចប់៧៦ គេចាប់ពួកនេះទៅ ប្រហែលជាចូល៧៧ហើយ ។

ទេវិទ្ធ ៖ ចាប់អ្នកណាគេ?

ផន ៖ ចាប់ពួកភ្នំ ពួកស្វាយធំ ចាប់នឹង ភ្នំរន្ទះ ។

ទេវិទ្ធ ៖ ត្រូវជាស្អីគេអ្នកនឹង អ្នកនឹងធ្វើអីបានគេចាប់?

ផន ៖ តាមួយអត់មានធ្វើអីទេ គាត់លក់ថ្នាំបុកថ្នាំបុកអី ប៉ុនតានឹងវាចូលដៃចូលជើងវាចេះ ដែលអាគៀនមួយវាឃ្មួនវានៅត្បូងនោះ ហើយវាមានប្រពន្ធនៅនឹង ហើយវាយកគោពីនឹងមកកាប់ស៊ី ហើយតានឹងចូលដៃចូលជើងគេកាប់គោគេ គេថាតានឹងគំនិតអាក្រក់ ហើយតានឹងចេះធ្វើថ្នាំ ធ្វើអី មើលជម្ងឺមើលអី ។ ហើយគេកាលនឹងគេមិនឲ្យអបិយជំនឿងនឹងអី គេបំបិទតាំងអស់នឹង ព្រលឹងនៅៗ តែកូនគាត់នៅធ្វើការភ្នំពេញ ។

ទេវិទ្ធ ៖ គេបំបិទអីខ្លះ គេប្រាប់មកយើងឃុំប្រាប់មក?

ផន ៖ បំបិទតាំងពីមានរៀបសែនព្រេនភូមិអារក្សអី ហើយបាលីស្ដោះផ្ដុំអីស្ដោះគោស្ដោះមនុស្សអី អត់បានទេ ។

ទេវិទ្ធ ៖ ខាងណាគេប្រាប់យើង?

ជន ៖ ខ្មែរក្រហមនឹង ។

ទេវិទ្ធ ៖ គេប្រាប់ថាគេបំបិទអីចឹង?

ជន ៖ អឺ! គេអត់ឲ្យមាន ។

ទេវិទ្ធ ៖ អ្នកណាអ្នកប្រាប់តា?

ជន ៖ មេឃុំ ។

ទេវិទ្ធ ៖ មេឃុំ?

ជន ៖ អឺ!

ទេវិទ្ធ ៖ ប្រាប់នឹងឆ្នាំណា?

ជន ៖ ប្រាប់ឆ្នាំដែលគេចាប់មនុស្សនឹងឆ្នាំ៧៦ គ្រាន់តែពួកនឹងមកដល់គេបំបិទរឿងនឹងទាំងអស់ ។

ធីតា ៖ កាលនឹងលោកតាទៅស្ពានណា នាំទៅវត្តប្រធាតុនឹង?

ជន ៖ ទៅតាមផ្លូវកោះកុសល ផ្លូវពីពេចន៍ផ្សារមកលិចមកថ្នល់ តែកាលនឹងទៅតាមផ្លូវដាច់នឹងទៅដល់ទូកចំលងត្រង់នឹងវាដាច់ មានតែប្រឡាយនឹងទេ ។

ធីតា ៖ លោកតាទៅតែម្នាក់ឯង?

ជន ៖ ហ៊ើ!អាទៅមើលនឹង២-៣នាក់ ។

ធីតា ៖ ម៉េចបានលោកតាទៅមើល?

ជន ៖ ទៅមើលគេដាក់ខ្មោះ ទៅមើលចុះប្រជាជនពីនេះទៅដែរ គេយកទៅដាក់នឹង ។ នេះតាមួយនៅនឹងភូមិនឹងយកទៅមួយដែរ គេយកទៅមន្ទីរដេកពេទ្យ ដល់ហើយអត់ពេកគាត់នាំគ្នាបះបោរសុំកន្ទក់សុំអីគេ ដល់ហើយថាតានឹងនាំបះបោរក៏យកទៅទាំងអស់ យកជាមួយពួក១៧ ។ មូលដ្ឋានក៏គេដាក់គុកនៅនឹងដែរ ទៅដេកពេទ្យ គេយកតានឹងទាំងរញីរញ៉ៃស្រីស្រាញ់ជមុជទឹក ហើយគេដោលទូកចម្លងទៅ ដល់ភូមិកោះកុសលនឹង ដល់លិចភូមិនឹងស្ពាននឹង គេហូតទឹកនឹងគេបញ្ជូនម៉េចដឹងរទេះសេះដាក់អី ។

ធីតា ៖ ដឹករទេះសេះយកទៅ?

ជន ៖ អឺ! ដឹកទៅម៉ង គេមិនដូចយើង យកទៅដល់គេវ៉ៃ ។

ទេវិទ្ធ ៖ តាឃើញដែរ?

ជន ៖ វ៉ៃតាំងពីផ្ទះទៅ ។

ទេវិទ្ធ ៖ យកអីវ៉ៃ?

ផន ៖ វ៉ៃដំបង វ៉ៃរំពាត់ វ៉ៃថ្នោង ដំបងប៉ុនៗមេដើងមេដៃ គេមិនវ៉ៃដំបងធំណា វ៉ៃប៉ាំងខ្នប់ ប៉ាំង ដួល គេមិនគិតថាខ្លាចងាប់ទេ ។ ហើយយកទៅដល់នឹង គេដាក់ខ្មោះទៅ បន្ទត់បាយទៀត មួយយប់គ្មានបានហូបបានអី ។ ហើយបាយយកទៅដាក់ អាចម៍នឹង ហូបនឹង ហើយចុះមាន ស្រាយខ្មោះណា អាចម៍នៅនឹង ។

ធីតា ៖ ពេលស្មានណាលោកតាត្រឡប់មកវិញ?

ផន ៖ ហើយអាចម៍ទាំងនោម ខ្ញុំទៅឃើញអនោចអាធម្ម ឃើញគ្នាឯងខ្ញុំមិនចង់ឲ្យទៅជួបទេ ព្រោះ នាំគ្នាឯង ឃើញខ្ញុំទៅថាខ្ញុំក្រែងខ្ញុំថែមពាក្យថែមសម្តី ខ្ញុំទៅគ្រាន់តែលបមើល ខ្ញុំមិនឲ្យជួប មុខផង លបមើលពីចំងាយ ។

ធីតា ៖ លបមើលឃើញ?

ផន ៖ អឺ! មើលឃើញ អាខ្លះហើម...ហើមមុខ ហើមមាត់ៗ បើអាទីនឹងកាលនៅនេះ វាធ្វើការ ជាមួយខ្ញុំដែរ បានខ្ញុំចិត្តមិនដាច់ទៅមើលនឹង ខ្ញុំមិនទៅក៏សួរគេថាអីចឹងដែរថាអាទីហើមមុខ... ដាក់ខ្មោះ ហើយខ្ញុំមិនចង់ឲ្យឃើញៗនាំគេថា ។ ហើយចាប់ ក្រៅពីនឹងគេក្រោយៗនឹង ចាប់ លួចស្រូវ លួចអីណា ពួកឈ្លបនឹងគេចាប់ ក៏ខ្ញុំតាមសុំគេ សុំគេមិនឲ្យ ដល់ចាប់គ្នាធ្វើ ម៉េចក្មេងល្ងង់ ហ៊ើ!អានឹងវាលួចស្រូវគេមិនចាប់ ព្រោះយើងក្តាប់គេ យើងត្រូវដឹង ។ ខ្ញុំថា ដោះស្រាយឲ្យគ្នាមួយពេលទៅ ទុកខ្ញុំអប់រំខ្ញុំសិនទៅ ជួនណាអាខ្លះវាស្តាប់ខ្ញុំវាទុកសិន ខ្លះគេ មិនស្តាប់ ។

ទេវិទ្ធ ៖ តាអីចឹងខ្ញុំអរគុណតាច្រើនហើយ ខ្ញុំអស់សំនួរសួរតាទៀតហើយ ។ តាមានអីចង់និយាយ ទៀតទេ?

ផន ៖ មានអី ចង់ដឹងថាក្មួយឯងមកនឹងចង់ដឹងរឿងនឹង តើគិតម៉េចអីម៉េច យកទៅសម្ភាសន៍ណាអី យកការណ៍ធ្វើម៉េចៗ ក្រែងក្មួយយកទៅគ្រាន់យកការណ៍ឲ្យដឹង ហើយដើម្បីយកថ្កោល ទោសថ្កោលទុកអីនឹង ខ្ញុំចង់សួរតែប៉ុននឹងទេ?

ទេវិទ្ធ ៖ តាដូចខ្ញុំជម្រាបតាពីដំបូង កន្លែងខ្ញុំជាកន្លែងមជ្ឈមណ្ឌលដែលស្រាវជ្រាវចងក្រងប្រមូលឯក សារប្រវត្តិសាស្ត្រ ស្អីដែលតានិយាយប្រាប់ខ្ញុំជារឿងរ៉ាវប្រវត្តិសាស្ត្រដែលកើតឡើងកាល ពីសម័យនោះ ។ អីចឹងពួកខ្ញុំប្រមូលយកទៅទុក ចងក្រងវាទុកឲ្យជំនាន់ក្រោយមើល ។

ផន ៖ ហ្អឹង! ជំនាន់តានេះចេះៗ ។

ទេវិទ្ធ ៖ ទុកឲ្យនេះ យើងសរសេរជាអត្ថបទ ។

ផន ៖ ហើយយាយខ្ញុំគាត់ភ័យអីចឹងថាស្រាវជ្រាវយកទៅធ្វើទោសធ្វើទុក្ខអីចេះចោះ ។

ទេវិទ្ធ ៖ អត់ទេ តា យើងធ្វើនេះគឺ នេះដូចទស្សនាវដ្ដីដូចអី ពេលទំនេរតាអញ្ជើញមើល ។

ផន ៖ បាទ! ស្រាវជ្រាវត្រង់អីចឹងមិនអី ខ្ញុំដឹងម៉េចខ្ញុំប្រាប់ទាំងអស់ ខ្ញុំមិនបេះលាក់ទេ ។

ធីតា ៖ ពួកខ្ញុំមិនមែនជា...ជាអង្គការក្រៅរដ្ឋាភិបាល អត់មានពាក់ព័ន្ធនឹងនយោបាយទេ ចង់ដឹងសរសេរ researchជាកូនសិស្ស ។

ទេវិទ្ធ ៖ ឲ្យកូនសិស្សស្រុកគេ គេមកស្រាវជ្រាវមើល ស្រុកយើងកើតអីខ្លះ ។

ផន ៖ ហើយខ្ញុំមិនបេះខ្លាចទេ តាំងពីជំនាន់ខ្មែរក្រហមមក ខ្ញុំមិនខ្លាចៗរឿងថាស្លាប់ដោយសារការងារដែរធ្វើ ខ្ញុំនិយាយតែត្រង់ ដល់អីចឹងហើយបានពួក១៧ ពួកថ្មីនឹងវាបេះស្រឡាញ់ខ្ញុំ ខ្ញុំមកមានតែជួយអប់រំថាធ្វើម៉េចអត់ឃ្លានតិចតួចទ្រាំទៅ យើងមកពីនោះដល់គឺយ៉ាប់ហើយយើងគ្រប់គ្នា បើយើងមិនកាន់ចិត្តត្រង់គេគឺស្លាប់មិនបានដល់ពេលរំដោះបានទេ ។ ខ្ញុំមានណែនាំប៉ុននឹង ត្រង់ថាបេះបោះអត់ គ្មានបន្ទោសទៅស្ដី ព្រោះមានបងប្អូនធ្វើការនៅក្នុងនេះច្រើនដែរនឹង ហើយជីដូនមួយខ្ញុំអស់ប៉ុន្មានហើយនឹង ជីដូនម៉ាមា-កគាត់ធ្វើធំៗគេយកវៃចោលអស់ដែរ ពូបាងខាងបាល់ទាត់ ។

អ្នកជិតខាងៈ គាត់ធ្វើល្អណាស់ គ្មានអ្នកណាធ្វើបាបគាត់ ។

ផន ៖ សួរតែគេនឹងដឹងហើយ ស្រុកណាក៏គេថាខ្ញុំធ្វើការបានស្អាត ។

អ្នកជិតខាងៈ គាត់ធ្វើល្អបេះ បាយទឹកវាមិនខ្វះអីមិនខ្វះ ទាល់តែម៉្យាងវៃចោលៗមើលឥឡូវគេធូរជើង កាង.... ។

ផន ៖ បើធ្វើធូរអីចឹងម៉េចនឹងបាន ម៉េចនឹងកើតប្រឡាយនឹងកើត អាពតគេធ្វើអីចឹងគេហៅប្ដេជ្ញាហើយការផ្ដាច់ការ អាពតធ្វើការផ្ដាច់ការ បើប្រហែលព្រះវិហារម៉េចលោកវៃចោល អានឹងគេហៅពួកទមិឡ ហើយគ្មានត្រង់ណាពូកែម៉េចក៏ទប់វាមិនបាន ។ មុនដំបូងឲ្យរំដោះពី៧មកវាមកឲ្យតែមានបាយជាមួយអំបិលក៏បាន ។ ហើយដល់ទល់ មានគ្រប់មុខហើយនៅតែពូកែនៅតែមិនសុខចិត្តទៀត វាដូចពិបាកអីចឹង ។

អ្នកជិតខាងៈ ដូចអូននៅតូចៗអីចឹងមិនដឹងប្រវត្តិប៉ុនអាពតវាស្អាតមែន គ្រាន់វៃមនុស្សចោលតិច ឲ្យស៊ីមិនឆ្អែតនឹង បើសិនជាមានកសាងម៉ាស៊ីនបេះអីខ្លះ និយាយពីការងារឥឡូវប្អូន ឯងសំឡឹងមើលតាំងពីប្រឡាយទឹក ប្រព័ន្ធភ្លឺ ទំនប់ទឹក ធារទឹក ទំនប់ទឹក គេធ្វើបានត្រឹមត្រូវ ។

ផន ៖ បេះឥឡូវយើងធ្វើគ្រាន់ស្ដារដែរខ្មែរក្រហម ។

អ្នកជិតខាងៈ សូម្បីមេភូមិមេឃុំនឹង ឲ្យគេរំលាយស្រេចតែចិត្ត គ្មាននឹងឃើញថាឥឡូវរាំងស្ទះស្រណុកយកទឹក ស្រណុកមានផ្លូវចុះដីកស្រូវដីកអីអត់ទេ អាណាធ្វើម៉េចធ្វើសេរីភាព... ហើយមិន

មែនរដ្ឋអំណាចនឹងធ្វើមិនកើតទេ ធ្វើកើត តែមិនធ្វើ គ្រាន់យើងទៅបោះថា នែក!អ្នកឯង រំលាយប្រឡាយអត់បាន យើងធ្វើផ្លូវច្បាប់ ស្អប់អ្នកតែម្នាក់អ្នកចង់ប្រឡាយរំលាយ អ្នកឯង ធ្វើខុសទៅគោរពធ្វើអី ។ ចុះអាគេអ្នកស្រែនៅជិតៗនឹង ដែលគេមិនបានប៉ុននឹង ហើយចុះមេឃុំទៅដល់រំលាយប៉ិប មេឃុំបោះបង្គោលលើប្អូនឯងធ្វើអត់សមស្រប ប្អូនឯងធ្វើអត់សមស្រប ងាប់អស់មនុស្សច្រើនណាស់ ទម្រាំកើតជាប្រឡាយកើតអី មិនត្រូវបំផ្លាញវាទេ ទុកកេរ្តិ៍តំណែលត្រូវគេធ្វើទៅមុខ ។

ផន : អីចឹងហើយបានគេប្រជុំឲ្យពង្រីកថែម ព្រោះអានេះតំណែលពីខ្មែរក្រហមវាធ្វើមកវាត្រឹមត្រូវ ។

ទេវិទ្ធ : សេរីពេក?

ផន : អឺ!ប៉ុនខ្មែរក្រហម កុំបានខ្មែរក្រហមក៏គ្មានប្រឡាយខាត់ខ្មែងទេ អូ!ឥឡូវធ្វើងាប់ ធ្វើមិនបាន ។

អ្នកជិតខាង: អូ!នៅនឹង...ដំបូកស្នាទរំលាយកើត រំលាយព្រៃសុទ្ធតែព្រៃឬស្សី សុទ្ធតែដំបូកវាកាប់ វារំលើង រំលាយធ្វើជាប្រព័ន្ធទឹកប្រឡាយទឹកល្អស្រួល.....។

ផន : វាខុសរឿង វាចាំចាត់ថ្នាក់រឿងប្រជាជនរឿងយកវៃចោល ។

ទេវិទ្ធ : អីចឹងខ្ញុំអរគុណតាច្រើន ។ តាមានអីឆ្ងល់ទៀតទេ?

ផន : ឆ្ងល់អីទេ គ្រាន់តែសួរឲ្យដឹង គេមកស្រាវជ្រាវរឿងប្រវត្តិនឹង វាត្រូវហើយ ខ្ញុំមិនខ្លាចប្រាប់ទេ ប្រវត្តិជំនាន់នឹង ហើយវាធ្វើការធ្វើស្រួល ។

ទេវិទ្ធ : អីចឹងអរគុណច្រើនតា ជម្រាបលា ។

«ចប់»